Food and Agriculture Organization of the United Nations

This programme is co-funded by the European Union




## កម្មវិធីជំរុញកំណើនវិស័យជលផលកម្ពុជា ប្រកបដោយចីរភាព និងបរិយាប័ន្នៈ ផ្នែកនេសាទ

### ការតាមដាន វាយតម្លៃផលនេសាទសមុទ្រ នៅកន្លែងឡើងផលនេសាទក្នុងប្រទេសកម្ពុជា

# របាយការណ៍ស្ថិតិផលនេសាទសមុទ្រ ប្រចាំឆ្នាំ២០២៣

ចងក្រងដោយ៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

*ការបោះពុម្ពផ្សាយនេះទទួលបានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។*

*ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ ជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផល ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

## សេចក្ដីថ្លែងអំណរគុណ

របាយការណ៍ស្ថិតិប្រចាំឆ្នាំនេះ ត្រូវបានរៀបចំឡើងដោយមានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ក្រោមកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន្ន (CAPFISH)។ អ្នកចងក្រងរបាយការណ៍នេះសូមអរគុណដល់គម្រោងគាំទ្របច្ចេកទេសពីអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO CAPFISH-Capture) ដែលបានគាំទ្រដល់ការអភិវឌ្ឍវិធីសាស្ត្រនិងការបណ្ដុះបណ្ដាល ព្រមទាំងផ្ដល់ការណែនាំដល់ការប្រមូលនិងការវិភាគទិន្នន័យ។ អ្នកចងក្រងរបាយការណ៍ក៏សូមថ្លែងនូវអំណរគុណដល់ក្រុមមន្ត្រីប្រមូលទិន្នន័យនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ (MaFReDI) សម្រាប់ការអនុវត្តការប្រមូលនិងបញ្ចូលទិន្នន័យយ៉ាងសកម្មរបស់ពួកគេ ព្រមទាំងការចូលរួមចំណែកបន្ថែមដល់ការបកស្រាយព័ត៌មាន។ អ្នកនិពន្ធសូមអរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីមានសមត្ថកិច្ចមូលដ្ឋានគ្រប់លំដាប់ថ្នាក់ចំពោះការគាំទ្រនិងកិច្ចសហការនៅអំឡុងការចុះអនុវត្តការងារនៅទីវាល។

**ចងក្រងដោយ**
***វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ***

ដោយមានជំនួយបច្ចេកទេសពីគម្រោង FAO CAPFISH

## គុណកថាបង្អែក

រដ្ឋបាលជលផល (២០២៣)។ របាយការណ៍ស្ថិតិផលនេសាទសមុទ្រក្នុងប្រទេសកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៤២ទំព័រ។

## ទំនាក់ទំនង

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ
អាគារលេខ ១៨៦ មហាវិថីនរោត្តម រាជធានីភ្នំពេញ ប្រទេសកម្ពុជា

© រដ្ឋបាលជលផល
រក្សាសិទ្ធគ្រប់យ៉ាង។ ការបោះពុម្ភឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ មិនតម្រូវឱ្យសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ ដោយគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើម។ រាល់ការបោះពុម្ភ ការចម្លង ឬចែកចាយសម្រាប់លក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀតត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។
រាល់មតិយោបល់ និងមតិដែលបានបង្ហាញនៅទីនេះ គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនអាចឆ្លុះបញ្ចាំងពីជំហររបស់រដ្ឋបាលជលផល ដៃគូ ឬអង្គការ ដែលផ្ដល់មូលនិធិសម្រាប់គម្រោ ងនិងការបោះពុម្ពផ្សាយនោះទេ។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** .................... i

**បញ្ជីតារាង** .................... iii

**បញ្ជីក្រាហ្វិក** .................... iii

**ឧបសម្ព័ន្ធ** .................... iii

**ពាក្យបំព្រួញ** .................... iv

**សេចក្តីសង្ខេប** .................... v

**១.សេចក្តីផ្តើម** .................... 1

**២. វិធីសាស្ត្រស្រាវជ្រាវ** .................... 1

**៣. លទ្ធផល** .................... 2

៣.១ ចំនួន ទូកនេសាទ/ការឡើងផលនេសាទអង្កេត នៅខែមិថុនា ដល់ ខែធ្នូ .................... 2

៣.២ របាយការណ៍ផលនេសាទ .................... 2

៣.៣ សមត្ថភាពផលចាប់ក្នុង១ឯកតានៃឧបករណ៍នេសាទសំខាន់ៗ .................... 3

៣.៤ សមាមាត្រផលនេសាទដោយឧបករណ៍នេសាទសំខាន់ៗ .................... 6

៣.៥ សមត្ថភាពនេសាទតាមឧបករណ៍នេសាទ .................... 8

៣.៦ សមាសភាគផលចាបតាមក្រុមប្រភេទ តាមទម្ងន់នៃផលនេសាទ .................... 9

៣.៧ សមាសភាគផលនេសាទតាមប្រភេទ តាមទម្ងន់ផលនេសាទ គ្រប់កន្លែងឡើងផលនេសាទ .... 10

៣.៨ សមាសភាគផលនេសាទតាមក្រុមប្រភេទ តាមតម្លៃឡើងផលនេសាទ .................... 11

៣.៩ សមាសភាគផលនេសាទតាមប្រភេទ តាមតម្លៃផលនេសាទ គ្រប់កន្លែងឡើងផលនេសាទ...... 12

៣.១០ ផលនេសាទប៉ាន់ប្រមាណសរុប .................... 13

៣.១១ ប្រភេទត្រីធ្វើចរាចរណ៍ឆ្លាយនិងផលស្តុកឆ្លងដែន .................... 14

**៤. សេចក្តីសន្និដ្ឋាននិងអនុសាសន៍** .................... 15

## បញ្ជីតារាង

តារាងទី១. ចំនួននៃការឡើងផលនេសាទ ដែលត្រូវបានកត់ត្រាតាមខេត្តនិងកន្លែងឡើងផលនេសាទ ........... 2
តារាងទី២. CPUE(គ.ក្រ/ថ្ងៃ) និងការរួមចំណែកទៅនឹងទម្ងន់ផលនេសាទសម្រាប់ឧបករណ៍ ខ្នាតតូចនិងខ្នាតមធ្យម ........ 4
តារាងទី៣. CPUE (គីឡូក្រាម/ថ្ងៃ) សម្រាប់ទូកអួនអូស តាមទំហំទូកនេសាទ ........ 5
តារាងទី៤. សមាមាត្រនៃផលនេសាទតាមឧបករណ៍សំខាន់ៗ សម្រាប់ឧបករណ៍នេសាទ ខ្នាតតូចនិងខ្នាតមធ្យម ........ 6
តារាងទី៥. ផលនេសាទតាមតំបន់នេសាទនិងប្រភេទឧបករណ៍នេសាទសំខាន់ៗ........ 8
តារាងទី៦. ចំនួនថ្ងៃធ្វើនេសាទមធ្យមប្រចាំខែប៉ាន់ប្រមាណតាមឧបករណ៍និងថ្នាក់ទូកនេសាទសំខាន់ៗ......... 8
តារាងទី៧. សមាសភាគផលចាប់តាមប្រភេទគ្រប់កន្លែងឡើងផលនេសាទទាំងអស់........ 11
តារាងទី៨. តម្លៃសរុប (១០០០រៀល) តាមប្រភេទនៅគ្រប់ការឡើងផលនេសាទទាំងអស់ ........ 12
តារាងទី៩. ផលចាប់ប៉ាន់ស្មានមធ្យមប្រចាំខែតាមប្រភេទទូក-ឧបករណ៍នេសាទសំខាន់ៗ........ 14
តារាងទី១០. របាយការណ៍ផលនេសាទ (គ.ក្រ) និងការប៉ាន់ប្រមាណផលនេសាទសរុប (តោន) សម្រាប់ប្រភេទដែលរួមបញ្ចូលនៅក្នុង UNFSA និង RPOA ........ 15
តារាងទី១១. ផលនេសាទប៉ាន់ប្រមាណសរុបប្រៀបធៀបរវាងស្ថិតិផ្លូវការនៃរដ្ឋបាលជលផលនិង FCMAS..... 16
តារាងទី១២. គោលដៅសំណាកគំរូប្រចាំខែ អាស្រ័យលើការប្រែប្រួលអង្កេតនៅឆ្នាំ២០២២-២៣ ........ 19

## បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១. ទម្ងន់ផលនេសាទកត់ត្រាសរុប (គ.ក្រ) តាមខេត្តនិងខែ........ 3
ក្រាហ្វិកទី២. របាយការណ៍ទីតាំងនេសាទ ដោយបញ្ចូលគ្នាឧបករណ៍ទាំងអស់និងបំបែកទូកអួនអូសចេញ...... 7
ក្រាហ្វិកទី៣. សមាសភាគផលនេសាទតាមក្រុមប្រភេទ តាមកន្លែងឡើងផលនេសាទទាំងអស់បញ្ចូលគ្នា....... 9
ក្រាហ្វិកទី៤. តម្លៃនៃផលនេសាទតាមក្រុមប្រភេទសំខាន់ៗ គ្រប់ការឡើងផលនេសាទទាំងអស់ ........ 12

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. សមាសភាគផលនេសាទ តាមក្រុមប្រភេទគ្រប់ការឡើងផលនេសាទ តាមទម្ងន់និងតម្លៃ ........ 23
ឧបសម្ព័ន្ធទី២. ការរួមចំណែកផលនេសាទតាមប្រភេទឧបករណ៍នេសាទនិងតាមខេត្ត ........ 24
ឧបសម្ព័ន្ធទី៣. សមត្ថភាពផលចាប់ក្នុង១ឯកតា (CPUE) តាមខេត្ត ........ 25
ឧបសម្ព័ន្ធទី៤. ផលនេសាទតាមប្រភេទ តាមខេត្ត........ 27
ឧបសម្ព័ន្ធទី៥.សមាសភាគរាយការណ៍ប្រចាំខែធៀបនឹងផលនេសាទតាមប្រភេទប្រចាំឆ្នាំ សម្រាប់ប្រភេទកំពូលគេទាំង២០........ 33
ឧបសម្ព័ន្ធទី៦. ផលនេសាទរាយការណ៍តាមទីតាំងនេសាទនិងតាមខេត្តសំខាន់ៗ ........ 34
ឧបសម្ព័ន្ធទី៧. សមាសភាគផលនេសាទតាមប្រភេទដោយទូកអួនអូស រួមចំណែកយ៉ាងតិច ៧០% នៃផលនេសាទ ........ 35

# ពាក្យបំព្រួញ

| | |
|---|---|
| CPUE | សមត្ថភាពផលចាប់ក្នុង១ឯកតា (Catch per Unit Effort) |
| EU | សហគមន៍អឺរ៉ុប |
| ε% | ស្តង់ដារលំអៀងប្រៀបធៀប (Relative Standard Error) |
| FAO | អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ |
| FCMAS | ការតាមដានវាយតម្លៃផលនេសាទសមុទ្រ |
| FiA | រដ្ឋបាលជលផល |
| FiAC | ខណ្ឌរដ្ឋបាលជលផល |
| KHR | រៀល |
| MaFReDI | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ |
| MT | តោន |
| nei | គ្មានក្នុងក្រុមដទៃ (not elsewhere included) |
| SD | គម្លាតស្តង់ដារ (Standard Deviation) |
| US$ | ដុល្លារសហរដ្ឋអាមេរិក |

# សេចក្តីសង្ខេប

ការប្រមូលទិន្នន័យសម្រាប់ FCMAS ត្រូវបានអនុវត្ត ចាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ អោយបានប្រមូលទិន្នន័យអំពីការឡើងផលនេសាទសរុបចំនួន ១៥៦៩ នៅកន្លែងឡើងផលនេសាទចំនួន ៨ ក្នុងនោះមានទិន្នន័យអង្កេតពីទូកនេសាទខ្នាតតូចចំនួន ៣៥២ និងទូកនេសាទខ្នាតមធ្យមចំនួន ១២១៧។ ទូកនេសាទខ្នាតតូចបានរួមចំណែក ៣,២% នៃផលចាប់រាយការណ៍សរុប ក្នុងនោះការនេសាទដោយទូកអួនអូសបានរួមចំណែករហូតដល់ ៧៨,៨% នៃផលចាប់ ដែលបានរាយការណ៍ និងឧបករណ៍នេសាទខ្នាតមធ្យមផ្សេងទៀតរួមចំណែក ១៩%។ ទិន្នន័យនេះបង្ហាញថាការនេសាទដោយអូកអួនអូសជាផ្នែកសំខាន់បំផុតក្នុងវិស័យជលផលកម្ពុជា។

ការឡើងផលនេសាទនៅខេត្តកោះកុងនិងខេត្តព្រះសីហនុ តំណាងឱ្យជាង ៩០% នៃចំនួនផលនេសាទរាយការណ៍សរុប ក្នុងនោះខេត្តកោះកុងរួមចំណែក ៣២.៩% និងខេត្តព្រះសីហនុ ៥៧.៤% ហើយខេត្តទាំងពីរនេះរួមចំណែក ៩៨% នៃផលនេសាទរាយការណ៍ដោយទូកអួនអូស។ ការឡើងផលនេសាទដែលបានរាយការណ៍ បង្ហាញពីបម្រែបម្រួលតាមរដូវកាលតិចតួច ដោយផ្អែកលើទម្ងន់ផលនេសាទដែលបានកត់ត្រាសរុប និងសារៈសំខាន់នៃប្រភេទជាក់លាក់ចំនួន ជាពិសេសសារៈសំខាន់នៃត្រីកាកីម។

ទិន្នន័យប្រមូលបានបង្ហាញថាឧបករណ៍នេសាទខ្នាតមធ្យមត្រូវបានប្រតិបត្តិការភាគច្រើននៅសមុទ្រក្រៅ (៥៣% នៃផលនេសាទបានរាយការណ៍) ចំណែកឯការនេសាទដោយឧបករណ៍ខ្នាតតូចភាគច្រើនធ្វើឡើងនៅក្នុងខេត្តតាមតំបន់ឆ្នេរ នៅក្នុងចន្លោះជម្រៅទឹក ២០ម៉ែត្រ (៦៣% នៃផលនេសាទ) ។

សមត្ថភាពនេសាទ (Effort) បង្ហាញអោយឃើញពីការប្រែប្រួលតិចតួចបំផុតរវាងប្រតិបត្តិការនេសាទខ្នាតតូច ឬខ្នាតមធ្យម និងឧបករណ៍នេសាទ ដោយប្រតិបត្តិករភាគច្រើនផ្តោតលើការនេសាទពេញម៉ោង។ ទោះជាយ៉ាងនេះក្តី តម្លៃនៃសមត្ថភាពផលចាប់ក្នុង១ឯកតា (CPUE) នៃឧបករណ៍មួយចំនួនមានការប្រែប្រួលខ្លាំង ក្នុងនោះទូកអួនអូស (២០៧,៦ គ.ក្រ/ថ្ងៃ) និងមងត្រីកាម៉ុង (១៥៣,៤ គ.ក្រ/ថ្ងៃ) ការរាយការណ៍បង្ហាញពីផលនេសាទខ្ពស់ខ្លាំងជាមួយនឹងទំនុកចិត្តស្ថិតិខ្ពស់។ តម្លៃ CPUE នៃការនេសាទខ្នាតតូចជាទូទៅទាបជាងសម្រាប់ឧបករណ៍ដូចគ្នា ដែលប្រើដោយទូកនេសាទខ្នាតមធ្យម ដោយទូកនេសាទកាន់តែធំអាចប្រើឧបករណ៍នេសាទបានកាន់តែច្រើន (លបនិងសន្ទូច) ឬមងកាន់តែវែង។ តម្លៃ CPUE ដែលខ្ពស់ជាងគេបំផុតសម្រាប់ទូកនេសាទខ្នាតតូច ដែលមានភាពត្រឹមត្រូវស្ថិតិខ្ពស់ គឺ មងត្រីកាម៉ុង (៦៩,៦ គ.ក្រ/ថ្ងៃ) បន្ទាប់មកគឺមងត្រី (៤៤,៨ គ.ក្រ/ថ្ងៃ) និងមងត្រីក្បក (៣៣,៨ គ.ក្រ/ថ្ងៃ)។

ឧបករណ៍នេសាទភាគច្រើនដំណើរការដោយទូកនេសាទខ្នាតតូចនិងខ្នាតមធ្យមបង្ហាញអោយឃើញពីភាពខុសគ្នាតិចតួច ក៏ប៉ុន្តែមានភាពខុសគ្នាខ្លាំងរវាងឧបករណ៍នេសាទសកម្មដូចជាទូកអួនអូស ដោយ CPUE នៃទូកអួនអូសខ្នាតកណ្តាលប្រវែង ១២-១៨ម៉ែត្រ ត្រូវបានប៉ាន់ប្រមាណថាមាន ៤២៧,៥ គីឡូក្រាមក្នុងមួយថ្ងៃ លើសពី ៧ដង នៃ CPUE សម្រាប់ទូកអួនអូសប្រវែង ៦-១២ម៉ែត្រ មាន ៦០,៥គីឡូក្រាម ក្នុងមួយថ្ងៃ។

ផលនេសាទប៉ាន់ប្រមាណជាមធ្យមប្រចាំខែ ចាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ មានចំនួន **៦៩៨៣,៤តោន**។ ជាលទ្ធផលនៃការគណនាសម្រាប់រយៈពេល ១២ខែ ផលនេសាទប៉ាន់ប្រមាណសរុបនៅឆ្នាំ២០២៣ មានចំនួន **៨៣.៨០០,៤៥ តោន**។ លទ្ធផលនេះគឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងផលនេសាទសរុបបូកយោងតគ្នា ដែលបានប៉ាន់ប្រមាណសម្រាប់ខែនីមួយៗ។ យោងតាមផលនេសាទបានរាយការណ៍ ការរួមចំណែកដ៏ធំច្រើនបំផុតដល់ផល

នៃសាទប៉ាន់ប្រមាណសរុបគឺផលនេសាទពីទូកអួនអូស សរុបចំនួន ៦០,៥% ជាមួយនឹងទូកនេសាទខ្នាតតូចបានរួមចំណែកជាង ១៧,៥% និងឧបករណ៍នេសាទខ្នាតមធ្យមផ្សេងទៀតបានរួមចំណែក ២៩,០%។ ទោះបីជាមានការប៉ាន់ប្រមាណមួយចំនួនសម្រាប់ទូកអួនអូសប្រវែង ១៨-២៤ម៉ែត្រ និងនាវានេសាទខ្នាតធំ >២៤ម៉ែត្រ ដោយផ្អែកលើទិន្នន័យអង្កេតការឡើងផលនេសាទដ៏តិចតួច ប្រភេទនៃទូកនេសាទ-ឧបករណ៍នេះបានរួមចំណែកដល់ផលនេសាទប៉ាន់ប្រមាណសរុប ត្រឹមតែ ៥% ប៉ុណ្ណោះ នាំអោយមានទំនុកចិត្តខ្ពស់ដល់លទ្ធផលនៃការប៉ាន់ប្រមាណផលនេសាទសរុបក្នុងរបាយការណ៍នេះ។

ដោយប្រើតម្លៃរាយការណ៍ជាមធ្យម (៤១៤៣ រៀល/គ.ក្រ) តម្លៃផលនេសាទប៉ាន់ប្រមាណសរុបសម្រាប់ឆ្នាំ២០២៣ មានចំនួន **៣៤៧.១៨៥.២៦៤.៣៥០** រៀល ឬ **៨៤.៦៧៩.៣៣៣** ដុល្លារអាមេរិក។

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ (MaFReDI) បាននិងកំពុងអនុវត្ត FCMAS ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីខណ្ឌជលផលក្នុងខេត្តតាមតំបន់ឆ្នេរ និងផ្តល់ទិន្នន័យនិងព័ត៌មានដ៏មានតម្លៃស្តីពីជលផលសមុទ្រ។ ជាលទ្ធផលនៃ FCMAS ការប៉ាន់ប្រមាណផលនេសាទសរុបមិនត្រូវគ្នានឹងការប៉ាន់ប្រមាណផលនេសាទផ្លូវការឆ្នាំ២០២៣ (១២៥.៥០០តោន) ឬសមាសភាពប្រភេទ ដែលត្រូវបានបោះពុម្ពដោយរដ្ឋបាលជលផល។ ការប៉ាន់ប្រមាណផលនេសាទនិងសមត្ថភាពនេសាទ ដោយ MaFReDI បច្ចុប្បន្ន មានកម្រិតនៃភាពជឿជាក់ខ្ពស់ ប៉ុន្តែលទ្ធផលទទួលបានពី FCMAS បច្ចុប្បន្នមិនទាន់ត្រូវបានប្រើ ដើម្បីបំពេញបន្ថែម ឬកែសម្រួលស្ថិតិជលផលថ្នាក់ជាតិនៅឡើយ។ ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ ការវាយតម្លៃនិងការសម្រេចចិត្តកាន់តែប្រសើរឡើងលើអន្តរាគមន៍គ្រប់គ្រង MaFReDI យល់ថាចាំបាច់ត្រូវធ្វើការកែតម្រូវមួយចំនួនលើការអនុវត្ត FCMAS ចាប់ឆ្នាំ២០២៤តទៅ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពី FAO CAPFISH។ របាយការណ៍នេះមានរួមបញ្ចូលនូវអនុសាសន៍មួយចំនួន ដោយមានកិច្ចសហការរៀបចំយ៉ាងជិតស្និទ្ធជាមួយ FAO CAPFISH ដែលត្រូវបានបង្ហាញនិងពិភាក្សាក្នុងសិក្ខាសាលាស្តីពី FCMAS ប្រចាំឆ្នាំ។

## ១.សេចក្តីផ្តើម

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ (MaFReDI) ដោយមានជំនួយបច្ចេកទេសនៃកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ននៃអង្គការស្បៀងនិងកសិកម្ម នៃសហប្រជាប្រជាជាតិ (FAO CAPFISH) ក្រោមការគាំទ្រថវិការបស់សហភាពអឺរ៉ុប (EU) កំពុងអនុវត្តការអង្កេតផលចាប់ជលផលសមុទ្រតាមបែបវិទ្យាសាស្ត្រ នៅតាមកន្លែងឡើងផលនេសាទក្នុងខេត្តតាមតំបន់ឆ្នេរទាំង៤ ចាប់តាំងពីខែមិថុនា ឆ្នាំ២០២១។ គោលបំណងនៃការអង្កេតនេះគឺដើម្បីធ្វើការប៉ាន់ប្រមាណ CPUE គិតជាគីឡូក្រាម/ថ្ងៃនេសាទ តាមឧបករណ៍នេសាទសំខាន់ៗ សមត្ថភាពនៃការធ្វើនេសាទប្រចាំខែ ផលនេសាទតាមប្រភេទនិងតម្លៃ ព្រមទាំងធ្វើការប៉ាន់ប្រមាណផលនេសាទសរុបពីទិន្នន័យប្រមូលបានពីកន្លែងឡើងផលនេសាទនៅខេត្តកំពត កែប កោះកុង និងព្រះសីហនុ។ របាយការណ៍នេះបង្ហាញអំពីលទ្ធផលចម្បងនៃការតាមដានផលនេសាទសមុទ្រនៅថ្នាក់ជាតិក្នុងប្រទេសកម្ពុជា ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣។

យោងតាមតម្រូវការអាទិភាពនិងសំណើរពីខណ្ឌរដ្ឋបាលជលផល ព័ត៌មានលម្អិតបន្ថែមអំពីលទ្ធផលតាមខេត្តនីមួយៗ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវ ការរចនាសំណាក និងទម្រង់អង្កេតសម្រាប់ការតាមដានផលចាប់ជលផលសមុទ្រ (FCMAS) មានបញ្ចូលនៅក្នុងសៀវភៅណែនាំ ដែលមានលើគេហទំព័រនៃរដ្ឋបាលជលផលតាមឯកសារយោងដូចខាងក្រោមៈ

រដ្ឋបាលជលផល (FiA) ឆ្នាំ២០២១. ឯកសារណែនាំការផលតាមដានចាប់ជលផលសមុទ្រក្នុងប្រទេសកម្ពុជា ចងក្រងដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៣៨ទំព័រ។

ការគ្របដណ្តប់នៃ FCMAS និងវិធីសាស្ត្រស្រាវជ្រាវមិនមានការផ្លាស់ប្តូរច្រើនទេ ចាប់តាំងពីការចាប់ផ្តើមនៃការស្ទង់មតិក្នុងឆ្នាំ២០២១។ ប៉ុន្តែមានការកែតម្រូវមួយចំនួនលើវិធីសាស្ត្រក្នុងវិស័យស្រាវជ្រាវ ដើម្បីបង្កើនភាពច្បាស់លាស់ដល់ការប៉ាន់ប្រមាណផលនេសាទ សមត្ថភាពនេសាទ ការផ្លាស់ប្តូរទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងសៀវភៅណែនាំ ដែលបានធ្វើបច្ចុប្បន្នភាព ហើយដែលនឹង ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០២៤ នេះ ជាមូលដ្ឋានសម្រាប់ការប្រមូលទិន្នន័យនាពេលអនាគត។

ទិន្នន័យឆ្នាំ២០២៣ ស្ទើរតែទាំងអស់ ត្រូវបានប្រមូលដោយប្រើការស្ទង់មតិតាមបែបរំលឹកឡើងវិញអំពីការឡើងផលនេសាទ ធ្វើឡើងដោយចៃដន្យនៅកន្លែងឡើងផលនេសាទចំនួន ៨ រយៈពេល ៤ថ្ងៃជាប់ៗគ្នា រហូតដល់ចុងខែនីមួយៗ។ ការស្ទង់មតិមិនធ្វើការវាស់វែងបរិមាណផ្ទាល់ ឬធ្វើការអង្កេតលើប្រភេទជាក់លាក់បន្ថែមឡើយ ហើយការអង្កេតបែបនេះអាចនឹងត្រូវអនុវត្តនៅពេលវាយតម្លៃលទ្ធផល។ ទិន្នន័យផ្អែកលើការស្ទង់មតិតាមបែបរំលឹកឡើងវិញមានភាពត្រឹមត្រូវទាបជាងការវាស់វែងបរិមាណដោយផ្ទាល់។ ទោះជាយ៉ាងនេះក្តី ទិន្នន័យទទួលបានមានភាពស៊ីសង្វាក់គ្នា រវាងកន្លែងឡើងផលនេសាទទៅនឹងខែ។ ការជ្រើសរើសយកសំណាកគំរូនិងការរចនាស្ទង់មតិនៃ FCMAS នឹងប៉ះពាល់ដល់របៀបដែលទិន្នន័យអាចត្រូវបានគេប្រើ និងប្រៀបធៀបជាមួយស្ថិតិជលផលផ្លូវការរបស់រដ្ឋបាលជលផល។ ជាលទ្ធផល វិធី

សាស្ត្រនេះអាចផ្តល់ទិន្នន័យដ៏មានប្រយោជន៍អំពីស្ថានភាពនិងនិន្នាការនៃជលផលសមុទ្រកម្ពុជា ដែលអាចជូនដំណឹងការប្រមូលទិន្នន័យនាពេលអនាគត គាំទ្រការបង្កើតនិងការកែសម្រួលគោលនយោបាយនិងផែនការគ្រប់គ្រងជលផល។

## ៣. លទ្ធផល

### ៣.១ ចំនួន ទូកនេសាទ/ការឡើងផលនេសាទអង្កេត នៅខែមិថុនា ដល់ ខែធ្នូ

ការប្រមូលទិន្នន័យសម្រាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ ធ្វើឡើងនៅទីតាំងឡើងផលនេសាទចំនួន៨ ដោយមានកន្លែងឡើងផលនេសាទចំនួន២ នៅខេត្តតាមតំបន់ឆ្នេរនីមួយៗ (តារាងទី១)។ សរុបរួម មានការអង្កេតការឡើងផលនេសាទពីទូកនេសាទខ្នាតតូចចំនួន ៣៥២ ឬត្រូវជា ២២,៤% និងទូកនេសាទខ្នាតមធ្យមចំនួន ១២១៧ ឬត្រូវជា ៧៧,៦% ត្រូវបានកត់ត្រា។ ទូកនេសាទខ្នាតមធ្យមរួមមានប្រវែង ១២-២៤ម៉ែត្រ រួមនឹងទូកនេសាទអួនអូសទាំងអស់ដោយមិនគិតពីទំហំ រួមនឹងទូកអូសគ្រែងឈាម។

តារាងទី១. ចំនួននៃការឡើងផលនេសាទ ដែលត្រូវបានកត់ត្រាតាមខេត្តនិងកន្លែងឡើងផលនេសាទ

| ខេត្ត | កន្លែងឡើងផលនេសាទ | ខ្នាតតូច | | ខ្នាតមធ្យម | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ឧបករណ៍ផ្សេងទៀត | | | អួនអូស | | | |
| | | < ៦ម | ៦-១២ម | ១២-១៨ម | ១៨-២៤ម | >២៤ម | ៦-១២ម | ១២-១៨ម | ១៨-២៤ម | |
| **កំពត** | កំពង់កណ្តាល | | 10 | 16 | 14 | | 133 | 23 | | 196 |
| | ត្រពាំងរពៅ | 1 | 116 | 74 | | | 5 | | | 196 |
| **កែប** | អំពែង | | 62 | 5 | | | 128 | 1 | | 196 |
| | អូរក្រសារ | | 45 | 136 | 16 | | | | | 197 |
| **កោះកុង** | ឧកញ៉ា លីយ៉ុងផាត់ | | 29 | 73 | 8 | 3 | 20 | 61 | 2 | 196 |
| | ថ្មស | | 81 | 87 | 5 | | 19 | 4 | | 196 |
| **ព្រះសីហនុ** | ស្ទឹងហាវ | | | 57 | | 1 | 11 | 127 | | 196 |
| | ទំនប់រលក | | 8 | 31 | 4 | | 107 | 46 | | 196 |
| **សរុបរួម** | | **1** | **351** | **479** | **47** | **4** | **423** | **262** | **2** | **1569** |

មានកំណត់ត្រាតិចតួចសម្រាប់ថ្នាក់ទូកនេសាទ-ឧបករណ៍ខ្លះ។ ជាក់ស្តែង ទូកនេសាទតូចជាង ៦ម៉ែត្រ មានកំណត់ត្រាត្រឹមតែ ១ប៉ុណ្ណោះ រីឯទូកនេសាទខ្នាតធំ មានកំណត់ត្រាត្រឹមតែចំនួន ៤ និងទូកអួនអូស (១៨-២៤ម៉ែត្រ) មានកំណត់ត្រាត្រឹមតែ ២ប៉ុណ្ណោះ។

### ៣.២ របាយការណ៍ផលនេសាទ

របាយការណ៍ផលនេសាទត្រូវបានប្រើធ្វើការប្រៀបធៀបរវាងខែនិងខេត្តមានបង្ហាញនៅក្នុងក្រាហ្វិកទី១ ផលនេសាទខ្ពស់កំពូលគេមានពីរខែគឺនៅខែកក្កដានិងខែតុលា។ ខណៈពេល ដែលខេត្តព្រះសីហនុមានផលនេសាទខ្ពស់ជាងគេជាច្រើនខែ មានការផ្លាស់ប្តូរចាប់ពីខែតុលា ទៅ ដែលភាគច្រើនទំនងជាដោយសារតែការថយចុះនៃផលនេសាទត្រីកាកីមនិងប្រភេទត្រីល្អិតផ្សេងទៀត ដែលគេដឹងថាមានផលនេសាទក្នុងចំនួនសន្ធឹកសន្ធាប់នៅកន្លែងឡើងផលនេសាទស្ទឹងហាវ ក្នុងខេត្តព្រះសីហនុ។ ទោះជាការផ្លាស់ប្តូរនេះបង្ហាញពីបម្រែបម្រួលតាមរដូវយ៉ាងច្បាស់នៃផល

នេសាទនៅខេត្តកោះកុងនិងខេត្តព្រះសីហនុ យ៉ាងណាក្តី ផលនេសាទ ដែលត្រូវបានរាយការណ៍ពីខេត្តកំពត និងខេត្តកែប នៅតែមានចំនួនប្រហាក់ប្រហែលគ្នា តាមខែនីមួយៗ។ ភាពផ្សេងគ្នាតាមរដូវតាមប្រភេទកាន់តែលម្អិតមានបញ្ចូលជូននៅក្នុងចំនុច ៣.៧ និងឧបសម្ព័ន្ធទី៥ នៃរបាយការណ៍នេះ។




ក្រាហ្វិកទី១. ទម្ងន់ផលនេសាទកត់ត្រាសរុប (គ.ក្រ) តាមខេត្តនិងខែ

## ៣.៣ សមត្ថភាពផលចាប់ក្នុង១ឯកតានៃឧបករណ៍នេសាទសំខាន់ៗ

ដោយសារ FCMAS ប្រើសំណាកគំរូថៃដន្យនៃការឡើងផលនេសាទ ចំនួនកំណត់ត្រាអង្កេតតាមឧបករណ៍នេសាទប្រែប្រួលតាមខែផ្សេងៗគ្នា ប៉ុន្តែឆ្លុះបញ្ចាំងពីប្រតិបត្តិការនិងភាពញឹកញាប់នៃឧបករណ៍ ដែលប្រើនៅតាមកន្លែងឡើងផលនេសាទ ដែលត្រូវបានគ្របដណ្តប់ដោយការស្ទង់មតិ។ លទ្ធផលបានបង្ហាញយ៉ាងច្បាស់ថាទូកអួនអូសគឺជាឧបករណ៍ដ៏សំខាន់បំផុត ដែលតំណាងឱ្យ ៥៦,៩% នៃឧបករណ៍ខ្នាតមធ្យម ដែលត្រូវបានកត់ត្រា ហើយបន្ទាប់មកគឺឧបករណ៍មងក្តាម ទោះមានគម្លាតឆ្ងាយពីគ្នាយ៉ាងណាក្តី។ សម្រាប់ទូកនេសាទខ្នាតតូច ឧបករណ៍ដែលប្រើញឹកញាប់បំផុតគឺមងត្រី ដែលត្រូវបានប្រើ ៣១,៥% នៃការឡើងផលនេសាទខ្នាតតូចទាំងអស់ បន្ទាប់មកគឺមងក្តាម (២២,៥%) និងលបត្រីម្រើមព្រះ (១៩,៤%)។

ទូកអួនអូសមាន CPUE ខ្ពស់បំផុតគឺ ១៩១,៧ គីឡូក្រាម/ថ្ងៃនេសាទ បន្ទាប់មកគឺមងត្រីផ្ទោង (១០១ គីឡូក្រាម/ថ្ងៃ) មងត្រី (៧៨ គីឡូក្រាម/ថ្ងៃ) មងត្រីកាម៉ុង (៦៩,៦ គីឡូក្រាម/ថ្ងៃ) និងរនងខ្សែចាប់មឹកពីងពាង (៤៦,៨ គីឡូក្រាម/ថ្ងៃ) ។ ឧបករណ៍នេសាទខ្នាតតូចដែលមានតម្លៃ CPUE ខ្ពស់ជាងគេគឺមងត្រី ៦០,២គីឡូក្រាម/ថ្ងៃ និងលបត្រីម្រើមព្រះ (១៧,៤គីឡូក្រាម/ថ្ងៃ) និង ហើយឧបករណ៍ទាំងនេះមានផលចាប់ប្រៀបធៀបគ្នាបាន បើពួកវានេសាទដោយទូកនេសាទខ្នាតមធ្យម។

តារាងទី២ បញ្ចូលរាល់ឧបករណ៍នេសាទណា ដែលមានចំនួនអង្កេតចាប់ពី ២ដងឡើងទៅ ព្រោះអាចឱ្យគេវាយតម្លៃភាពត្រឹមត្រូវនៃស្ថិតិ ដោយធ្វើការគណនាស្តង់ដារលំអៀងប្រៀបធៀប (ε%) នៃ CPUE ជាមធ្យម។ តាមលទ្ធផលអង្កេត មងត្រីផ្ទោងមាន CPUE ខ្ពស់បំផុត គឺ ២៤៥,៦ គីឡូក្រាម/ថ្ងៃនេសាទ។ ប៉ុន្តែតម្លៃ ε% នៃឧបករណ៍នេះខ្ពស់ខ្លាំង បង្ហាញថាការប៉ាន់ប្រមាណនេះមិនគួរអោយទុកចិត្តបានសម្រាប់តម្លៃ CPUE ជាក់ស្តែង នៃឧបករណ៍នេះ បន្ទាប់មកទូកអួនអូស (២០៧,៦ គ.ក្រ/ថ្ងៃ) មងត្រីកាម៉ុង (១៥៣,៤ គ.ក្រ/ថ្ងៃ) និងលបត្រី (១៥៣,២ គ.ក្រ/ថ្ងៃ)។ ដូចគ្នាដែរ

លបត្រីមានតម្លៃ ε% ខ្ពស់ខ្លាំង នាំឱ្យការប៉ាន់ប្រមាណមិនគួរឱ្យទុកចិត្តសម្រាប់តម្លៃ CPUE មធ្យមជាក់ស្តែងនៃឧបករណ៍នេះ។ CPUE សម្រាប់ការនេសាទខ្នាតតូចជាទូទៅគឺទាបជាងសម្រាប់ឧបករណ៍ដូចគ្នា ដែលប្រើដោយទូកនេសាទខ្នាតមធ្យម ដោយទូកនេសាទកាន់តែធំអាចប្រើឧបករណ៍នេសាទបានកាន់តែច្រើន (លបនិងសន្ទូច) ឬមងកាន់តែវែង។ លបត្រីម្រើមព្រះមាន CPUE ខ្ពស់ជាងគេបំផុតសម្រាប់ទូកនេសាទខ្នាតតូច (៨៤,៤ គ.ក្រ/ថ្ងៃ) ក៏មានតម្លៃ ε% ខ្ពស់ខ្លាំងផងដែរ បន្ទាប់មកមងត្រីកាម៉ុង (៦៩,៦ គ.ក្រ/ថ្ងៃ) មងត្រី (៤៤,៨ គ.ក្រ/ថ្ងៃ) និងមងត្រីក្បក (៣៣,៨ គ.ក្រ/ថ្ងៃ)។

ថ្នាក់ឧបករណ៍មួយ ដែលត្រូវបានដកចេញពីតារាងទី២ គឺជាឧបករណ៍មិនមានបញ្ជាក់ជាក់លាក់ ដែលស្ថិតក្នុងចំណោមឧបករណ៍មាន CPUE ខ្ពស់ខ្លាំង គឺ ២៧៩,៥ គីឡូក្រាម/ថ្ងៃនេសាទ សម្រាប់ទូកនេសាទខ្នាតមធ្យម និង ១៧២,២ គីឡូក្រាម/ថ្ងៃនេសាទ សម្រាប់ទូកនេសាទខ្នាតតូច។ ដោយសារនេះទំនងជាការរួមបញ្ចូលគ្នានៃឧបករណ៍នេសាទផ្សេងៗគ្នា លទ្ធផលនេះមិនអាចបកស្រាយថាជាឧបករណ៍តែមួយបានទេ។ នេះបង្ហាញថាចាំបាច់ត្រូវកំណត់ឧបករណ៍នេសាទអោយបានត្រឹមត្រូវ។ ក្នុងចំណោមការឡើងផលនេសាទសរុបចំនួន ១៥៦៩ មានកំណត់ត្រាចំនួន ១២ (០,៨%) មិនបានកំណត់អត្តសញ្ញាណឧបករណ៍។ ឧបករណ៍នេសាទ ដែលមិនបានបញ្ជាក់ ត្រូវបានដាក់រួមបញ្ចូលនៅក្នុងក្រុមប្រភេទឧបករណ៍ផ្សេងៗ (gears nei)។

តារាងទី២. CPUE (គីឡូក្រាម/ថ្ងៃ) និងការរួមចំណែកទៅនឹងទម្ងន់ផលនេសាទរាយការណ៍ សម្រាប់ឧបករណ៍ខ្នាតតូចនិងខ្នាតមធ្យម

| ថ្នាក់ទូកនេសាទ | ប្រភេទឧបករណ៍នេសាទ | CPUE | N | ទម្ងន់ផលនេសាទ | SD | ε% |
|---|---|---|---|---|---|---|
| ខ្នាតមធ្យម | មងត្រីផ្ទោង | 245.6 | 13 | 1.1% | 529.1 | 59.8% |
| | អួនអូស | 207.6 | 691 | 56.9% | 322.9 | 5.9% |
| | មងត្រីកាម៉ុង | 153.4 | 50 | 4.1% | 142.9 | 13.2% |
| | លបត្រី | 153.2 | 7 | 0.6% | 198.1 | 48.9% |
| | រនងខ្សែចាប់មឹកពីងពាង | 56.4 | 67 | 5.5% | 37.4 | 8.1% |
| | មងត្រី | 50.3 | 27 | 2.2% | 33.6 | 12.9% |
| | មងបង្គា | 49.5 | 54 | 4.4% | 44.1 | 12.1% |
| | សន្ទូចអូសមឹក | 32.2 | 3 | 0.2% | 11.1 | 19.9% |
| | សន្ទូចរនងមឹក | 26.9 | 2 | 0.2% | 23.9 | 62.8% |
| | លបក្តាម | 23.7 | 74 | 6.1% | 13.9 | 6.8% |
| | ឈិបយន្ត | 20.9 | 4 | 0.3% | 3.8 | 9.0% |
| | លបត្រីម្រើមព្រះ | 20.7 | 27 | 2.2% | 11.7 | 10.9% |
| | មងក្តាម | 18.5 | 167 | 13.8% | 12.3 | 5.1% |
| | លបមឹក | 14.8 | 5 | 0.4% | 1.7 | 5.2% |
| | ឈ្នាងអូសគ្រែងឈាម | 7.7 | 10 | 0.8% | 4.8 | 19.9% |
| | ឧបករណ៍ផ្សេងទៀត | | 13 | 1.2% | | |

| ថ្នាក់ទូកនេសាទ | ប្រភេទឧបករណ៍នេសាទ | CPUE | N | ទម្ងន់ផលនេសាទ | SD | ε% |
|---|---|---|---|---|---|---|
| **ថ្នាក់ទូកនេសាទ** | **ប្រភេទឧបករណ៍នេសាទ** | **CPUE** | **N** | **ទម្ងន់ផលនេសាទ** | **SD** | **ε%** |
| **ខ្នាតតូច** | រនងខ្សែចាប់មឹកពីងពាង | 84.4 | 6 | 1.7% | 105.8 | **51.1%** |
| | មងត្រីកាម៉ុង | 69.6 | 9 | 2.6% | 51.9 | 24.8% |
| | មងត្រី | 44.8 | 109 | 31.5% | 28.8 | 6.2% |
| | មងត្រីក្បក | 33.8 | 4 | 1.2% | 15.9 | 23.6% |
| | ឈិបយន្ត | 21.7 | 10 | 2.9% | 6.8 | 9.9% |
| | សន្ទូចត្រី | 15.8 | 4 | 1.2% | 6.0 | 19.1% |
| | លបត្រីម្រើមព្រះ | 15.5 | 67 | 19.4% | 8.0 | 6.3% |
| | សន្ទូចរនងមឹក | 15.5 | 11 | 3.2% | 21.6 | **42.1%** |
| | សន្ទូចរនងត្រី | 15.0 | 2 | 0.6% | 7.1 | **33.3%** |
| | លបក្ដាម | 13.1 | 31 | 9.0% | 6.4 | 8.8% |
| | មងបង្គា | 11.7 | 3 | 0.9% | 7.6 | **37.8%** |
| | លបមឹក | 10.7 | 2 | 0.6% | 1.0 | 6.7% |
| | មងក្ដាម | 9.4 | 78 | 22.5% | 7.2 | 8.7% |
| | ឈឺបរុញ | 4.8 | 2 | 0.6% | 1.1 | 15.8% |
| | ឧបករណ៍ផ្សេងទៀត | | 8 | 2.1% | | |

តម្លៃស្តង់ដរលំអៀងប្រៀបធៀប (ε%) បង្ហាញពីភាពជាក់លាក់នៃស្ថិតិ ឬគម្លាតរំពឹងទុកនៃ CPUE ជាមធ្យម ដែលប៉ាន់ស្មានជុំវិញតម្លៃពិតនៃ CPUE។ ប្រសិនបើតម្លៃ ε% ខ្ពស់ជាង ២៥% បង្ហាញថាតម្លៃប៉ាន់ស្មានមធ្យមមិនជឿទុកចិត្តនិងមិនគួរប្រើ។ ដូចតារាងទី២ បង្ហាញមានឧបករណ៍នេសាទតិចតួចប៉ុណ្ណោះ ដែលមានការប្រែប្រួលខ្ពស់ទាក់ទងទៅនឹងការប៉ាន់ប្រមាណ CPUE ភាគច្រើនទំនងជាបណ្តាលមកពីភាពខុសគ្នានៃចំនួននៃការប្រើឧបករណ៍នេសាទ។ ភាពជាក់លាក់នៃស្ថិតិគឺអាចទទួលយកបានសម្រាប់ឧបករណ៍នេសាទភាគច្រើន សម្រាប់ឧបករណ៍មានផ្ទៃខាងក្រោយពណ៌ទឹកក្រូច បង្ហាញពីការប៉ាន់ប្រមាណតម្លៃ CPUE ជាមធ្យមមិនអាចទុកចិត្តបានសម្រាប់ CPUE ពិតប្រាកដសម្រាប់ឧបករណ៍នោះ ហើយតម្លៃទាំងនេះត្រូវបានរួមបញ្ចូលក្នុងតារាងសម្រាប់ជាឯកសារយោង។

តារាងទី៣. CPUE (គីឡូក្រាម/ថ្ងៃ) សម្រាប់ទូកអួនអូស តាមទំហំទូកនេសាទ

| Trawlers | CPUE | N | SD | ε% |
|---|---|---|---|---|
| ខ្នាតតូច ៦-<១២ម អួនអូស | 60.5 | 423 | 89.1 | 7.2% |
| ខ្នាតមធ្យម ១២-១៨ម អួនអូស | 427.5 | 262 | 354.4 | 5.1% |
| ខ្នាតមធ្យម ១៨-<២៤ម អួនអូស | 220.8 | 2 | 277.0 | **88.7%** |
| ខ្នាតធំ ២៤ម+ | 1340.7 | 4 | 1,709.7 | **63.8%** |

ឧបករណ៍នេសាទដំណើរការដោយទូកនេសាទខ្នាតតូចនិងមធ្យម មានភាពខុសគ្នាតិចតួច លើកលែងតែឧបករណ៍នេសាទសកម្ម ដូចជាទូកអួនអូស។ CPUE នៃទូកអួនអូសមានភាពខុសគ្នាខ្លាំងរវាងថ្នាក់ទំហំទូកនេសាទ (តារាងទី

៣) ទូកអួនអូសខ្នាតមធ្យម ១២-១៨ម៉ែត្រ មាន CPUE ខ្ពស់ជាង ៤២៧,៥ គីឡូក្រាម/ថ្ងៃ ដែលច្រើនជាង ៧ដង នៃ CPUE ទូកអួនអូសប្រវែង ៦-១២ម៉ែត្រ ដែលមានផលនេសាទ ៦០,៥ គីឡូក្រាម/ថ្ងៃ។ ទោះបីជាដាក់តម្លៃ CPUE នៃទូកអួនអូសប្រវែង ១៨-២៤ម៉ែត្រ និង >២៤ម៉ែត្រ រួមបញ្ចូលក៏ដោយ តម្លៃ ៩% បង្ហាញថាការប៉ាន់ប្រមាណទាំងនេះមិនមានភាពត្រឹមត្រូវតាមស្ថិតិ ហើយមិនគួរប្រើតម្លៃទាំងនេះ ដោយសារការប្រែប្រួលខ្ពស់និងចំនួនសង្កេតតិច។

## ៣.៤ សមាមាត្រផលនេសាទដោយឧបករណ៍នេសាទសំខាន់ៗ

ការនេសាទដោយទូកអួនអូសរួមចំណែកខ្ពស់បំផុតទៅនឹងផលនេសាទរាយការណ៍សរុប ក្នុងនោះមងត្រីជាឧបករណ៍រួមចំណែកខ្ពស់បំផុតទៅនឹងផលនេសាទសរុបពីទូកនេសាទខ្នាតតូច។ នេសាទខ្នាតមធ្យមរួមចំណែកជាង ៩៧,៨% នៃផលនេសាទកត់ត្រាសរុប។

ខណៈពេលដែលឧបករណ៍នេសាទភាគច្រើនរួមចំណែកខ្ពស់ដល់តម្លៃផលនេសាទ រីឯទូកអួនអូសវិញរួមចំណែកខ្ពស់ដល់ទម្ងន់ផលនេសាទ ដោយហេតុថាឧបករណ៍អួនអូសភាគច្រើនចាប់បានត្រីតម្លៃទាប ដែលភាគច្រើនមិនត្រូវបានប្រើសម្រាប់មនុស្សបរិភោគ។ ការប្រៀបធៀបនេះក៏បង្ហាញផងដែរថា ឧបករណ៍នេសាទមួយចំនួនចាប់បានប្រភេទគោលដៅជាក់លាក់មួយចំនួន ដែលមានតម្លៃខ្ពស់ជាមួយនឹងបរិមាណទាប ឧ. រនងខ្សែចាប់ មងក្តាម មងបង្គា លបត្រី និងលបក្តាម។ ប្រភេទសំខាន់ៗ ដែលជាគោលដៅនេសាទដោយទូកអួនអូស មានលម្អិតជូននៅក្នុងការពិភាក្សា។

តារាងទី៤. សមាមាត្រនៃផលនេសាទតាមឧបករណ៍សំខាន់ៗ សម្រាប់ឧបករណ៍នេសាទខ្នាតតូចនិងខ្នាតមធ្យម

| **ខ្នាតមធ្យម** | **ផលនេសាទ (%)** | **តម្លៃ (%)** |
|---|---|---|
| អួនអូស | 78.8% | 52.0% |
| មងត្រីកាម៉ុង | 7.4% | 7.7% |
| រនងខ្សែចាប់មឹកពីងពាង | 2.8% | 7.5% |
| មងត្រីផ្ទោង | 2.1% | 2.9% |
| មងក្តាម | 0.9% | 2.3% |
| លបត្រី | 0.9% | 6.5% |
| លបក្តាម | 0.8% | 2.1% |
| មងបង្គា | 0.7% | 4.8% |
| មងត្រី | 0.6% | 3.0% |
| សន្ទូចអូសមឹក | 0.2% | 0.8% |
| ឧបករណ៍ផ្សេងទៀត | 2.5% | 2.1% |
| | 97.7% | 91.7% |
| **ខ្នាតតូច** | **Catch (%)** | |
| មងត្រី | 0.8% | 0.4% |
| មងត្រីកាម៉ុង | 0.3% | 0.3% |
| រនងខ្សែចាប់មឹកពីងពាង | 0.3% | 0.7% |
| មងក្តាម | 0.2% | 1.4% |

| | | |
|---|---|---|
| លបត្រីទ្រើមព្រះ | 0.2% | 0.3% |
| ឧបករណ៍ផ្សេងទៀត | 0.5% | 3.7% |
| | 2.3% | 6.8% |

| | សរុប | កំពត | កែប | កោះកុង | ព្រះសីហនុ |
|---|---|---|---|---|---|
| អួនអូស | 529,988 | 1.3% | 0.7% | 31.6% | 66.4% |
| ឧបករណ៍ខ្នាតមធ្យមផ្សេងទៀត | 128,012 | 32.0% | 4.6% | 37.5% | 25.9% |
| ឧបករណ៍ខ្នាតតូច | 14,921 | 44.2% | 10.2% | 38.6% | 7.0% |
| សរុប | 672,921 | 8.1% | 1.7% | 32.9% | 57.4% |

ទិន្នន័យនេះមិនបញ្ចូលការឡើងផលនេសាទពីទូកនេសាទប្រើច្រើនជាង ១ឧបករណ៍

ការនេសាទដោយទូកអួនអូសរួមចំណែកភាគច្រើនដល់ផលនេសាទប្រមាណជា ៧៨,៨% នៃផលនេសាទ។ ទន្ទឹមនឹងការនេសាទខ្នាតមធ្យមផ្សេងទៀតបានរួមចំណែក ១៩% នៃផលនេសាទ ដែលបានរាយការណ៍។ ជាលទ្ធផល ៩៧,៨% នៃផលនេសាទ ដែលបានរាយការណ៍ បានពីការនេសាទខ្នាតមធ្យម ជាមួយនឹងការនេសាទខ្នាតតូចរួមចំណែកត្រឹមតែ ៣,២% ប៉ុណ្ណោះ។

លើសពីនេះ បើពិនិត្យមើលផលនេសាទតាមខេត្ត ចាប់ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ ផលនេសាទបានពីការនេសាទដោយទូកអួនអូសភាគច្រើនត្រូវបានរាយការណ៍ពីខេត្តព្រះសីហនុ បន្ទាប់មកខេត្តកោះកុង ទោះជាមានគម្លាតពីគ្នាខ្លាំងក្តី ជាមួយនឹងខេត្តកំពតនិងកែបរួមចំណែកត្រឹមតែ ២% ប៉ុណ្ណោះ។ ផលនេសាទភាគច្រើននៃការនេសាទខ្នាតមធ្យមផ្សេងទៀត គឺមាននៅខេត្តកំពតនិងកោះកុង ចំណែកឯការនេសាទខ្នាតតូចភាគច្រើនមានរាយការណ៍នៅក្នុងខេត្តកោះកុង (សូមមើលព័ត៌មានលម្អិតបន្ថែម ឧបសម្ព័ន្ធទី៣)។







ក្រាហ្វិកទី២. របាយការណ៍ទីតាំងនេសាទ ដោយយកឧបករណ៍ទាំងអស់បញ្ចូលគ្នា និងបំបែកទូកអួនអូសចេញ

ទីតាំងទូទៅដែលទូកនេសាទដំណើរការ ជាពិសេសថាតើផលនេសាទត្រូវបានរាយការណ៍ថាបានមកពីសមុទ្រក្នុង ឬសមុទ្រក្រៅ ហើយរបាយការណ៍នេះមានរួមបញ្ចូលក្នុងក្រាហ្វិកទី២។ តាមរបាយការណ៍នេះបង្ហាញថាសមាមាត្រនៃផលនេសាទដ៏ច្រើនត្រូវបានរាយការណ៍ពីតំបន់សមុទ្រក្នុង (ក្នុងខ្សែបន្ទាត់ជម្រៅទឹក ២០ម៉ែត្រ) រួមទាំងទូកអួនអូសផងដែរ។ ដូចដែលចង្អុលបង្ហាញនៅក្នុងតារាងទី៥ ផលនេសាទបានពីភាគច្រើននៃទូកអួនអូសនិងឧបករណ៍ខ្នាតមធ្យមផ្សេងទៀត ត្រូវបានគេរាយការណ៍ថាបានពីតំបន់សមុទ្រក្រៅ។ ព័ត៌មានលម្អិតបន្ថែមអំពីភាពខុសគ្នារវាងខេត្តនីមួយៗមានបញ្ចូលក្នុងឧបសម្ព័ន្ធទី៦ ប៉ុន្តែការនេសាទនៅតំបន់សមុទ្រក្រៅដោយទូកនេសាទឡើងផលនេសាទនៅខេត្តកំពតនិងកែប គឺមិនសូវមានទេ។

តារាងទី៥. ផលនេសាទតាមតំបន់នេសាទនិងប្រភេទឧបករណ៍នេសាទសំខាន់ៗ

| ប្រភេទឧបករណ៍សំខាន់ៗ | សមុទ្រក្នុង | សមុទ្រក្រៅ | ទាំងពីរទីតាំង | ផលនេសាទរាយការណ៍សរុប (គ.ក្រ) |
|---|---|---|---|---|
| ឧបករណ៍ខ្នាតតូច | 63.1% | 9.8% | 27.1% | 15,235.3 |
| ឧបករណ៍អួនអូស | 26.4% | 55.5% | 18.1% | 529,988.4 |
| ឧបករណ៍ខ្នាតមធ្យមផ្សេងទៀត | 20.6% | 44.7% | 34.8% | 129,465.0 |

### ៣.៥ សមត្ថភាពនេសាទតាមឧបករណ៍នេសាទ

FCMAS ប្រមូលទិន្នន័យអំពីចំនួនថ្ងៃនេសាទ ដែលត្រូវបានប្រើសម្រាប់គណនាសមត្ថភាពនេសាទតាមប្រភេទឧបករណ៍ (តារាងទី៦) ។ របាយការណ៍នេះបង្ហាញថាសមត្ថភាពនេសាទគឺស្រដៀងគ្នាខ្លាំងតាមឧបករណ៍និងថ្នាក់នាវាផ្សេងៗគ្នា ដោយមានឧបករណ៍តិចតួចប៉ុណ្ណោះ ដែលខ្ពស់ជាង (លបមឹក) ឬទាបជាង (មងក្តាម) តម្លៃសមត្ថភាពនេសាទមធ្យមលើឧបករណ៍ទាំងអស់ ជាមួយនឹងតម្លៃសមត្ថភាពនេសាទមធ្យមត្រឹមត្រូវគឺ៖ ១៦,៥ ថ្ងៃនេសាទសម្រាប់ឧបករណ៍ខ្នាតតូច និង ១៨ ថ្ងៃនេសាទ សម្រាប់ឧបករណ៍ខ្នាតមធ្យម។ សមត្ថភាពនេសាទឯករាជ្យខ្លាំងពីប្រភេទទូកនេសាទ-ឧបករណ៍ ដោយប្រតិបត្តិករភាគច្រើនផ្តោតលើការនេសាទពេញម៉ោង។

តារាងទី៦. ចំនួនថ្ងៃធ្វើនេសាទមធ្យមប្រចាំខែប៉ាន់ប្រមាណតាមឧបករណ៍និងថ្នាក់ទូកនេសាទសំខាន់ៗ

| ឧបករណ៍នេសាទ | ខ្នាតតូច | | ខ្នាតមធ្យម | |
|---|---|---|---|---|
| | ចំនួនថ្ងៃ | ε% | ចំនួនថ្ងៃ | ε% |
| ទូកអួនអូស | | | 19.7 | 1.0% |
| ឈ្នាងអូសគ្រែងឈាម | | | 18.1 | 13.2% |
| លបត្រី | | | 16.6 | 22.1% |
| សន្ទូចត្រី | 9.0 | **32.4%** | | |
| លបមឹក | 22.5 | 6.7% | 26.4 | 4.3% |
| សន្ទូចរនងត្រី | 16.0 | 6.3% | | |
| លបក្តាម | 17.0 | 6.2% | 17.4 | 3.9% |
| ឈិបរុញ | 7.5 | **33.3%** | | |

| ឧបករណ៍នេសាទ | ខ្នាតតូច | | ខ្នាតមធ្យម | |
|---|---|---|---|---|
| | ចំនួនថ្ងៃ | ε% | ចំនួនថ្ងៃ | ε% |
| មងក្តាម | 13.0 | 5.3% | 11.5 | 4.2% |
| សន្ទូចរនងមឹក | 15.0 | 8.6% | 18.0 | 33.3% |
| មងត្រី | 19.4 | 3.2% | 15.6 | 8.8% |
| មងត្រីកាម៉ុង | 20.3 | 10.6% | 19.1 | 4.5% |
| មងត្រីក្បក | 12.3 | 6.1% | | |
| មងត្រីផ្ទោង | | | 21.5 | 10.5% |
| លបត្រីម្រើមព្រះ | 15.6 | 4.3% | 16.4 | 9.6% |
| មងបង្គា | 11.7 | 42.1% | 22.4 | 1.5% |
| សន្ទូចអូសមឹក | | | 18.7 | 18.9% |
| រនងខ្យងចាប់មឹកពីងពាង | 15.5 | 23.1% | 16.7 | 5.5% |
| ឈិបយន្ត | 15.2 | 10.6% | 15.3 | 21.6% |

## ៣.៦ សមាសភាគផលចាបតាមក្រុមប្រភេទ តាមទម្ងន់នៃផលនេសាទ

ផលនេសាទរាយការណ៍សរុប គ្រប់ក្រុមប្រទភេទទាំងអស់គឺ **៦៧៤.៧៦០.៧ គីឡូក្រាម** ត្រីជាក្រុមប្រភេទគ្របដណ្តប់លើផលចាប់រាយការណ៍សរុប ដែលមានស្មើរតែ ៧៣,៧% នៃទំងន់ផលចាប់សរុប បន្ទាប់មកក្រុមប្រភេទមឹក ៨,៨% ក្រុមបង្គា ៤,៤% ក្រុមក្តាម ២,៥% និងក្រុមប្រភេទផ្សេងទៀត ១,៦% (មានរួមបញ្ចូលក្រុមប្រភេទមិនមានបញ្ជាក់ច្បាស់លាស់ ឆ្លាមនិងបបែល)។ សម្រាប់ព័ត៌មានលម្អិតបន្ថែមសូមមើលឧបសម្ព័ន្ធទី១។




ក្រាហ្វិកទី៣. សមាសភាគផលនេសាទតាមក្រុមប្រភេទ នៅតាមកន្លែងឡើងផលនេសាទទាំងអស់បញ្ចូលគ្នា

### ៣.៧ សមាសភាគផលនេសាទតាមប្រភេទ តាមទម្ងន់ផលនេសាទរាយការណ៍ គ្រប់កន្លែងឡើងផលនេសាទ

សមាសភាគប្រភេទសម្រាប់ផលនេសាទរាយការណ៍សរុប ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ មានបង្ហាញនៅក្នុងតារាងទី៥។ សរុបមាន ៦៦ប្រភេទដាច់ៗពីគ្នា រួមនឹង ៤២ក្រុមប្រភេទ[1] ត្រូវបានរាយការណ៍។ ប្រភេទដែលសម្បូរបំផុតគឺត្រីកាកឹម (*Encrasicholina heteroloba*) ដែលរួមចំណែក ៤២,៤% នៃផលនេសាទរាយការណ៍សរុប។ បន្ទាប់មកមានក្រុមប្រភេទមួយចំនួនរួមមាន ក្រុមប្រភេទត្រីចំរុះ (១១,៦%) ងាវចំរុះ (៨,៦%) ត្រីជី (៥,៨%) មឹកពីងពាង (៣,៦%) ក្រុមមឹក ២,៩% និងត្រីផ្លាធូឬត្រីកាម៉ុងខ្លួនខ្លី ២,៨%។ ប្រភេទ ដែលមានផលនេសាទកំពូលគេទាំង ២០ប្រភេទ រួមចំណែក ៩៥,៣% នៃផលនេសាទរាយការណ៍សរុប។

ប្រភេទដាច់ៗពីគ្នារួមចំណែក **៣៧៩.៤៣៤,៧** គីឡូក្រាម (៥៦,២%) រីឯក្រុមប្រភេទរួមចំណែក **២៩៥.៣២៦** គីឡូក្រាម (៤៣,៨%) ទៅនឹងផលនេសាទរាយការណ៍សរុប។

ទាក់ទងនឹងការប្រែប្រួលតាមរដូវតាមប្រភេទ ឧបសម្ព័ន្ធទី៥ រួមបញ្ចូលសមាមាត្ររាយការណ៍ប្រចាំខែ ទៅនឹងផលនេសាទតាមប្រភេទប្រចាំឆ្នាំ សម្រាប់ប្រភេទកំពូលគេទាំង ២០ប្រភេទ ដើម្បីកំណត់បានថាខែណាខ្លះ ឬរយៈពេលណា មានរបាយការណ៍ពីសមាមាត្រប្រភេទខ្ពស់ជាងមធ្យមនៃផលនេសាទប្រចាំឆ្នាំ។ របាយការណ៍នេះមិនបញ្ចូលការវិភាគនេះទេ ក៏ប៉ុន្តែមានរួមបញ្ចូលឧទាហរណ៍នៃរបៀប ដែលទិន្នន័យអាចត្រូវបានប្រើប្រាស់។ ទោះបីជាប្រភេទខ្លះមានផលនេសាទនៅកំពូលគេ តាមខែខ្លះ (ត្រីកាកឹម ត្រីកាម៉ុងឬត្រីប្លាធូ ត្រីឈាម សប្បីសត្វ) ក៏ដោយ វាមិនច្បាស់ថាតើសំណាកគំរូបានជះឥទ្ធិពលដោយការជ្រើសការឡើងផលនេសាទដោយចៃដន្យ យ៉ាងដូចម្តេច នេះអាចបណ្តាលឱ្យមានការដាក់បញ្ចូល ឬអវត្តមានឧបករណ៍នេសាទខ្លះ។

ឧបសម្ព័ន្ធទី៧ រួមបញ្ចូលប្រភេទសំខាន់ៗ ដែលបានពីការនេសាទដោយទូកអួនអូស ដែលបានរួមចំណែកយ៉ាងតិចក៏ ៧០% នៃផលនេសាទប្រចាំឆ្នាំរាយការណ៍សរុប។ របាយការណ៍បង្ហាញថា ឧបករណ៍អួនអូសចាប់បាន ត្រីកាកឹម ត្រីឈាម គី និងសប្បីសត្វ (ក្តាម បង្គា) ជាមួយនឹងប្រភេទនិងក្រុមប្រភេទមួយចំនួន ដែលមានការរួមចំណែកខ្ពស់ដល់ផលនេសាទសរុប ឧ. ត្រីជី (៩៧,៨%) ប្រភេទត្រីចំរុះ (៩១,៨%) ក្រុមមឹក និងមឹកបំពង់ (៩១,២%) ដែលស្ទើរតែឡើងផលនេសាទទាំងស្រុបដោយទូកអួនអូស។ នេះបង្ហាញថាសមាមាត្រដ៏ខ្ពស់នៃផលនេសាទពីទូកអួនអូស មិនប្រើប្រាស់សម្រាប់មនុស្សទេ ហើយផលនេសាទភាគច្រើនមានតម្លៃទាប (២០០០រៀល/គីឡូក្រាម ឬទាបជាងនេះ)។ ត្រីកាកឹម ប្រភេទត្រីចំរុះ សប្បីសត្វ និងត្រីជី ត្រូវជា ៨៥% នៃផលនេសាទពីទូអួនអូស។

---

[1] មានការត្រួតស៊ីគ្នារវាងក្រុមប្រភេទមួយចំនួន ជាពិសេសក្រុមមឹក ដែលធ្វើឱ្យវាពិបាកក្នុងការញែកចំនួនពិតប្រាកដនៃក្រុមប្រភេទផ្សេងៗគ្នា

តារាងទី៧. សមាសភាគផលចាប់តាមប្រភេទគ្រប់កន្លែងឡើងផលនេសាទទាំងអស់

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ | ផលចាប់(គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|
| *Encrasicholina heteroloba* | Shorthead anchovy | កាកីម | 286,375.0 | 42.4% |
| | Other fish nei | ប្រភេទត្រីចំរុះ | 78,184.5 | 11.6% |
| | Shellfish nei | ងាវចំរុះ | 58,131.0 | 8.6% |
| | Trash fish | ត្រីជី | 38,840.0 | 5.8% |
| | Octopus nei | មឹកពីងពាង | 24,349.3 | 3.6% |
| *Decapterus macrosoma* | Shortfin scad | ត្រីកាម៉ុងឬត្រីប្លាធូ | 22,740.5 | 3.4% |
| | Squids nei | មឹក | 19,713.0 | 2.9% |
| *Rastrelliger brachysoma* | Short mackerel | ត្រីផ្លាធូឬត្រីកាម៉ុងខ្លួនខ្លី | 19,117.5 | 2.8% |
| *Portunus pelagicus* | Swimming crab | ក្តាមសេះ | 13,970.6 | 2.1% |
| | Cephalopods (squids/cuttlefish) | ពពួកមឹកស្នូកនិងមឹកចំពង់ | 11,479.2 | 1.7% |
| | Needlefish nei | ត្រីផ្ទោង | 11,203.0 | 1.7% |
| *Penaeus sp.* | Prawns nei | បង្គា | 10,893.5 | 1.6% |
| | Other catch nei | ផ្សេងៗ | 10,596.6 | 1.6% |
| | Shrimps (unsorted) | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | 6,959.0 | 1.0% |
| | Tuna | ត្រីឈាម | 5,800.0 | 0.9% |
| *Rastrelliger faughni* | Island mackerel | ត្រីប៉ាឡាំង | 5,775.0 | 0.9% |
| *Metapenaeus spp.* | | បង្គាឪខាក់ | 5,457.2 | 0.8% |
| *Anodontostoma chacunda* | Chacunda gizzard shad | ត្រីកាម៉យ | 5,612.0 | 0.8% |
| | Small mixed shrimp nei | គី | 4,334.0 | 0.6% |
| *Rastrelliger kanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង | 4,020.0 | 0.6% |
| | Other species | ប្រភេទផ្សេងទៀត | 31,209.8 | 4.6% |
| **សរុបរួម** | | | **674,760.7** | |

## ៣.៨ សមាសភាគផលនេសាទតាមក្រុមប្រភេទ តាមតម្លៃឡើងផលនេសាទ

តម្លៃសរុបរាយការណ៍ ពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ មានចំនួន **២.៧៩៥.៦៥២.៥០០** រៀល ក្នុងនោះត្រីរួមចំណែក ៣២,៨% ក្រុមមឹក ៣២,0% ក្រុមក្តាម ១៥,៧% និងក្រុមបង្គា ១៤,៣% ជាមួយនឹងក្រុមសប្បីសត្វ រួមចំណែក ២,៧% និងក្រុមត្រីចំរុះ ២,៥% (រួមបញ្ចូលក្រុមប្រភេទមិនមានបញ្ជាក់ ឆ្លាម និងបបែល)។ ព័ត៌មានលម្អិតបន្ថែមមានបញ្ចូលក្នុងឧបសម្ព័ន្ធទី២។




ក្រាហ្វិកទី៤. តម្លៃនៃផលនេសាទតាមក្រុមប្រភេទសំខាន់ៗ គ្រប់ការឡើងផលនេសាទទាំងអស់

## ៣.៩ សមាសភាគផលនេសាទតាមប្រភេទ តាមតម្លៃផលនេសាទ គ្រប់កន្លែងឡើងផលនេសាទ

តម្លៃរាយការណ៍សរុបនិងថ្លៃសម្រាប់ប្រភេទនៅកំពូលគេទាំង ២០ប្រភេទ នៅខែធ្នូ មានបង្ហាញនៅក្នុងតារាងទី៦។ ប្រភេទ (ក្រុម) ដែលមានតម្លៃរាយការណ៍ខ្ពស់ជាងគេគឺក្តាមសេះ (១៣,៩%) បន្ទាប់មកគឺក្រុមមឹក (១២,៣%) ត្រីកាកឹម (៨,២%) ទម្ងន់ផលនេសាទរាយការណ៍ដ៏ខ្ពស់នាំអោយមានការរួមចំណែកខ្ពស់ទៅផលនេសាទសរុប។ ក្រៅពីក្រុមប្រភេទមឹកមួយចំនួន មឹកស្នូកនិងមឹកពីងពាង និងក្រុមប្រភេទត្រីចំរុះ (៧,០%) បង្គាចំរុះ (៥,០%) ក៏ជាក្រុមប្រភេទសំខាន់ បើសិនដោយសារបរិមាណផលចាប់ដ៏ច្រើន ក៏ដោយសារតម្លៃដ៏ខ្ពស់ ផងដែរ។ ក្រុមប្រភេទផ្សេងទៀត និងក្រុមប្រភេទមិនស្ថិតក្នុងក្រុមប្រភេទកំពូលគេទាំង២០ រួមចំណែក ៩,៤% នៃតម្លៃផលនេសាទរាយការណ៍សរុប។

តារាងទី៨. តម្លៃសរុប (១០០០រៀល) តាមប្រភេទនៅគ្រប់ការឡើងផលនេសាទទាំងអស់

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | តម្លៃ (១០០០ រៀល) | តម្លៃ (%) | ថ្លៃ (រៀល/kg) |
|---|---|---|---|---|---|
| *Portunus pelagicus* | ក្តាមសេះ | Swimming crab | 388,666 | 13.9% | 24,175 |
| | មឹក | Squids nei | 347,372 | 12.4% | 17,325 |
| *Encrasicholina heteroloba* | កាកឹម | Shorthead anchovy | 228,204 | 8.2% | 750 |
| | ប្រភេទត្រីចំរុះ | Other fish nei | 196,055 | 7.0% | 2,750 |
| | ពពួកមឹកស្នូកនិងមឹកបំពង់ | Cephalopods (squids/cuttlefish) | 178,770 | 6.4% | 15,025 |
| | ពពួកមឹកពីងពាង | Octopus | 292,865 | 6.1% | 12,100 |
| *Penaeus sp.* | បង្គា | Prawns nei | 138,477 | 5.0% | 17,225 |
| *Metapenaeus spp.* | បង្គាឱខាក់ | | 126,291 | 4.5% | 22,225 |
| *Decapterus macrosoma* | ត្រីកាម៉ុងឬត្រីប្លាធូ | Shortfin scad | 98,499 | 3.5% | 4,550 |
| *Rastrelliger brachysoma* | ត្រីផ្លាធូ ឬត្រីកាម៉ុងខ្លួនខ្លី | Short mackerel | 88,656 | 3.2% | 4,750 |

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | តម្លៃ (១០០០ រៀល) | តម្លៃ (%) | ថ្លៃ (រៀល/kg) |
|---|---|---|---|---|---|
| *Suborder Sepiina* | មឹកស្នូក | Cuttlefish | 69,940 | 2.5% | 15,550 |
| | ផ្សេងៗ | Other catch nei | 67,570 | 2.4% | 14,575 |
| | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | Shrimps (unsorted) | 67,166 | 2.4% | 8,400 |
| | ខ្យង មឹក ក្តាមផ្សេងៗ | Shellfish nei | 59,486 | 2.1% | 1,525 |
| | ត្រីផ្តោង | Needlefish nei | 48,774 | 1.7% | 7,150 |
| *Portunus spp.* | ក្តាមសេះ | Swimming crabs | 37,806 | 1.4% | 24,275 |
| *Rastrelliger faughni* | ត្រីប៉ាឡាំង | Island mackerel | 30,055 | 1.1% | 5,550 |
| *Rastrelliger kanagurta* | ត្រីកាម៉ុងខ្លួនវែង | Indian mackerel | 25,610 | 0.9% | 5,625 |
| | ត្រីជី | Trash fish | 22,071 | 0.8% | 800 |
| *Rachycentron canadum* | ត្រីផ្ទក់សមុទ្រ | Cobia | 20,022 | 0.7% | 32,000 |
| | ប្រភេទផ្សេងទៀត | Other species | 263,301 | 9.4% | |
| **សរុបរួម** | | | **2,795,652.5** | | |

## ៣.១០ ផលនេសាទប៉ាន់ប្រមាណសរុប

យោងលើសារៈសំខាន់នៃនេសាទដោយទូកអួនអូស ឧបករណ៍អួនអូសត្រូវបានបែងចែកតាមថ្នាក់ទំហំមូលដ្ឋានចំនួន ៣កម្រិត[2] បន្ថែមលើថ្នាក់ទូកនេសាទស្តង់ដាររបស់រដ្ឋបាលជលផល។ ទិន្នផលតាមទូកនេសាទប្រចាំខែគឺផ្អែកលើការប៉ាន់ប្រមាណផលនេសាទមធ្យមប្រចាំថ្ងៃ និងចំនួនថ្ងៃនេសាទប្រចាំខែ រីឯការបូកសរុបប្រើចំនួនទូកនេសាទតាមប្រភេទទូកនេសាទនីមួយៗ ផ្អែកលើទិន្នន័យជំរឿនទូកនេសាទឆ្នាំ២០១៨ ដោយធ្វើការសន្មត់ថាមានទូកនេសាទ ៨៥% ជាទូកនេសាទសកម្ម[3]។

ផលនេសាទមធ្យមប្រចាំខែ នៅអំឡុងខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០២៣ គឺ **៦៩៨៣,៤** តោន។ ធ្វើការគណនាសម្រាប់រយៈពេល ១២ខែ នាំអោយផលនេសាទប៉ាន់ប្រមាណសរុបសម្រាប់ឆ្នាំ២០២៣ គឺ **៨៣.៨០០,៤៥**តោន។ ចំនួននេះស្ទើរតែដូចទៅនឹងការបូកយោងបន្តគ្នាតាមខែនីមួយៗពីខែមករា ដល់ខែឧសភា ដោយផ្អែកលើផលនេសាទប៉ាន់ប្រមាណមធ្យមប្រចាំខែ។

យោងតាមផលចាប់ ដែលបានរាយការណ៍ ការនេសាទដោយអួនអូសមានការរួមចំណែកខ្ពស់ជាងគេបំផុតទៅនឹងផលនេសាទប៉ាន់ស្មានសរុបគឺចំនួន ៦០,៥% ជាមួយនឹងទូកនេសាទខ្នាតតូចបានរួមចំណែកជាង ១៧,៥%។ ដោយសារតែចំនួនសង្កេតមិនគ្រប់គ្រាន់សម្រាប់ប្រភេទទូកនេសាទ-ឧបករណ៍មួយចំនួនតាមខែខ្លះ ការគណនាផលនេសាទសរុបប្រចាំខែក្នុងតារាងទី៧ ប្រើប្រាស់តម្លៃមធ្យមប្រចាំឆ្នាំសម្រាប់ CPUE និងសមត្ថភាពនេសាទ (Effort) សម្រាប់នាវានេសាទខ្នាតតូច < ៦ម៉ែត្រ ទូកអួនអូស ១៨-២៤ម៉ែត្រ និងនាវានេសាទខ្នាតធំ >២៤ម៉ែត្រ។ មានការ

---

[2] ទិន្នន័យឆ្នាំ២០២៣ មិនមានការកត់ត្រាឧបករណទូកអួនអូសតាមប្រភេទ

[3] ផ្អែកលើព័ត៌មានផ្តល់ដោយមន្ត្រីខណ្ឌរដ្ឋបាលជលផល

កត់ត្រាការអង្កេតការឡើងផលនេសាទសម្រាប់ថ្នាក់ទូក-ឧបករណ៍ទាំងនេះតិចតួចប៉ុណ្ណោះ ក្នុងមួយឆ្នាំកន្លងទៅ ដូចនេះតម្លៃ ε% តំណាងឱ្យតម្លៃប្រចាំឆ្នាំ។

តម្លៃ ε%, តាមប្រភេទទូកនេសាទ-ឧបករណ៍ភាគច្រើន អាចទទួលយកបាន ក៏ប៉ុន្តែពេលធ្វើការប៉ាន់ប្រមាណប្រចាំឆ្នាំ មិនមានភាពជាក់លាក់នៃស្ថិតិគ្រប់គ្រាន់សម្រាប់ទូកនេសាទ ដែលមានទំហំវែងជាង ១៨ម៉ែត្រ និងទូកនេសាទផ្សេងទៀតធំជាង ២៤ម៉ែត្រ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារថ្នាក់ទូកនេសាទ-ឧបករណ៍ទាំងនេះរួមចំណែកតិចជាង ៥,២% នៃផលចាប់ប៉ាន់ស្មានសរុប ធ្វើអោយមានការជឿជាក់ថាតម្លៃប៉ានប្រមាណនេះកៀកខ្លាំងទៅនឹងតម្លៃជាក់ស្តែង។

ដោយប្រើថ្លៃរាយការណ៍មធ្យម តម្លៃសរុបនៃផលចាប់ប៉ាន់ប្រមាណគឺ **៣៤៧.១៨៥.២៦៤.៣៥០** រៀល ឬ **៨៤.៦៧៩.៣៣៣** ដុល្លារសហរដ្ឋអាមេរិក។

តារាងទី៩. ផលចាប់ប៉ាន់ស្មានមធ្យមប្រចាំខែតាមប្រភេទទូក-ឧបករណ៍នេសាទសំខាន់ៗ

| **Vessel-gear category** | **ចំនួនអង្កេត** | **CPUE** | **ε%** | សមត្ថភាពនេសាទ (Effort) | ទិន្នផលតាមនាវាប្រចាំខែ (គ.ក្រ) | ទូកសកម្ម (៨៥%) | ទិន្នផលសរុបប្រចាំខែ (តោន) | %សរុប |
|---|---|---|---|---|---|---|---|---|
| ខ្នាតតូចខ្លាំង <៦ម | 1 | 5.5 | 7.0% | 5.0 | 27.5 | 775.2 | 21.3 | 0.3% |
| ខ្នាតតូច ៦-<១២ម | 351 | 27.5 | 7.0% | 16.4 | 451.6 | 2658 | 1,200.3 | 17.2% |
| អួនអូស ៦-<១២ម | 423 | 60.5 | 7.2% | 19.3 | 1,169.4 | 952 | 1,113.3 | 15.9% |
| អួនអូស ១២-១៨ម | 262 | 427.5 | 5.1% | 20.4 | 8,725.9 | 339.15 | 2,959.4 | 42.4% |
| អួនអូស ១៨-<២៤ម | 2 | 220.8 | **88.7%** | 16.0 | 3,533.3 | 42.5 | 150.2 | 2.2% |
| ឧបករណ៍ផ្សេងទៀត ១២-១៨ម | 479 | 47.2 | 11.4% | 16.0 | 755.7 | 1588.7 | 1,200.6 | 17.2% |
| ឧបករណ៍ផ្សេងទៀត ១៨-<២៤ម | 47 | 121.6 | 18.6% | 18.9 | 2,301.9 | 55.25 | 127.2 | 1.8% |
| ខ្នាតធំ លើស ២៤ម | 4 | 1,340.7 | **63.8%** | 17.5 | 23,462.5 | 9 | 211.2 | 3.0% |
| **ផលនេសាទប៉ាន់ប្រមាណសរុបប្រចាំខែ** | | | | | | | **6,983.4** | |

## ៣.១១ ប្រភេទត្រីធ្វើចរាចរណ៍ឆ្លាយនិងផលស្តុកឆ្លងដែន

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តុកត្រីរបស់អង្គការសហប្រជាជាតិ (UNFSA) នៅថ្ងៃទី១៨ខែមករា ឆ្នាំ២០២០ ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងដំណើរការការតម្កល់ឯកសារនេះទៅអង្គការសហប្រជាជាតិ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) កំណត់ការស្តុកទុកជាន់គ្នាថាជា "ស្តុកដូចគ្នា ឬស្តុកនៃប្រភេទ ដែលពាក់ព័ន្ធគ្នា កើតមានឡើងទាំងនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងក្នុងតំបន់ខាងក្រៅនិងនៅជាប់នឹងតំបន់សេដ្ឋកិច្ចពិសេសនោះ" ខណៈ ដែលស្តុកមានការធ្វើចំណាកស្រុកខ្ពស់ បង្ហាញជូនក្នុងឧបសម្ព័ន្ធ១ នៃ UNCLOS ដែលតម្រូវអោយប្រទេសហត្ថលេខីចាត់វិធានការដើម្បីធានាបាននូវការអភិរក្សនិងការគ្រប់គ្រង។ លើសពីនេះ កម្ពុជាបានចូលរួមនៅក្នុងផែនការសកម្មភាពថ្នាក់តំបន់ចំនួនពីរ (RPOA) សម្រាប់ការ

គ្រប់គ្រងស្តុកត្រីឆ្លងដែន៖ ១) RPOA- សម្រាប់ការគ្រប់គ្រងត្រីប្លាធូ និង ២) RPOA លើត្រីធូណា។ កិច្ចព្រមព្រៀងទាំងពីរត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ ក្នុងនាមប្រទេសជាសមាជិក រួមទាំងប្រទេសកម្ពុជា (SEAFDEC ២០១៥) និងអនុវត្តកាតព្វកិច្ចក្នុងការរាយការណ៍អំពីបរិមាណនៃផលនេសាទ ទាក់ទងនឹងស្តុកត្រីជាន់គ្នា និងស្តុកធ្វើចំណាកស្រុកខ្ពស់។

យោងតាមទិន្នន័យពី FCMAS ក្នុងឆ្នាំ២០២៣ ផលនេសាទប្រមាណជា ៣% ជាប្រភេទ ដែលបានរៀបរាប់នៅក្រោម UNFSA និង RPOA តារាងទី១១។ សមាសភាគនៃប្រភេទទាំងនេះ ដែលមាននៅក្នុងការតាមដាន វាយតម្លៃផលនេសាទសមុទ្រ ត្រូវបានធ្វើការគណនា ដោយប្រើការប៉ាន់ប្រមាណផលនេសាទសមុទ្រសរុប (បើមិនដោយផ្អែកលើទិន្នន័យទទួលបានពី FCMAS ក៏ផ្អែកលើទិន្នន័យប៉ាន់ប្រមាណផ្លូវការរបស់រដ្ឋបាលជលផល ដែរ)។ ផលនេសាទប៉ាន់ប្រមាណសរុប ដែលដាក់បញ្ចូលក្នុងតារាងទី១១ គឺយោងលើការប៉ាន់ប្រមាណ ផ្អែកលើទិន្នន័យទទួលបានពី FCMAS។

តារាងទី១០. របាយការណ៍ផលនេសាទ (គ.ក្រ) និងការប៉ាន់ប្រមាណផលនេសាទសរុប (តោន) សម្រាប់ប្រភេទ ដែលរួមបញ្ចូលនៅក្នុង UNFSA និង RPOA

| **ឈ្មោះវិទ្យាសាស្ត្រ** | **ឈ្មោះភាសាអង់គ្លេស** | **ឈ្មោះភាសាខ្មែរ** | **របាយការណ៍ផលចាប់ (kg)** | | **ផលចាប់ប៉ាន់ប្រមាណសរុប (តោន)** |
|---|---|---|---|---|---|
| | | | សរុប | %សរុប | |
| *Bramidae* | Pomfrets | ត្រីចាប | 15 | 0.002% | 1.9 |
| *Rastrelliger brachysoma* | Short mackerel | ត្រីផ្លាធូ ឬត្រីកាម៉ុងខ្លួនខ្លី | 19,118 | 2.83% | 2,374.3 |
| *Scomberomorus commerson* | Narrow-barred Spanish mackerel | ត្រីបេកាខ្មៅ ឬត្រីបេកាឆ្នូត | 46 | 0.007% | 5.7 |
| **ផលចាប់រាយការណ៍សរុប** | | | 19,521 | 3.07% | 19,179 |

## ៤. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

ដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្របាននិងកំពុងអនុវត្តFCMAS ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរខណ្ឌជលផលនៅខេត្តតាមតំបន់ឆ្នេរ បានផ្តល់នូវទិន្នន័យនិងព័ត៌មានដ៏មានតម្លៃស្តីពីជលផលសមុទ្រ។ ទិន្នន័យទទួលបានពី FCMAS មិនត្រូវបានប្រើប្រាស់ដើម្បីបំពេញបន្ថែម ឬកែសម្រួលស្ថិតិជលផលជាតិនៅឡើយ ហើយជាលទ្ធផល ការវិភាគ ដែលបានរួមបញ្ចូលក្នុងរបាយការណ៍ស្ថិតិប្រចាំខែ ត្រូវបានធ្វើឡើងជាចម្បងគឺដើម្បីបំពេញតាមគោលដៅរបស់សហភាពអឺរ៉ុប ដែលតម្រូវអោយបង្កើតរបាយការណ៍ទាំងនេះ។ បញ្ហាចម្បងទាក់ទងនឹងការទទួលយកលទ្ធផលបានពី FCMAS គឺថាការប៉ាន់ប្រមាណផលនេសាទសរុបត្រូវគ្នានឹងការប៉ាន់ស្មានផលនេសាទផ្លូវការ ឬសមាសភាពប្រភេទ ដែលត្រូវបានបោះពុម្ពដោយរដ្ឋបាលជលផល។ ភាពខុសគ្នាបង្ហាញកាន់តែច្បាស់សម្រាប់ទិន្នន័យឆ្នាំ២០២៣ ដែលខុសគ្នាខ្លាំងជាងការប៉ាន់ប្រមាណឆ្នាំ២០២២ (តារាងទី១១)។

តារាងទី១១. ផលនេសាទប៉ាន់ប្រមាណសរុបប្រៀបធៀបរវាងស្ថិតិផ្លូវការរបស់រដ្ឋបាលជលផលនិង FCMAS

| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ |
|---|---|---|
| ស្ថិតិជាតិរបស់រដ្ឋបាលជលផល | 125,200 | 125,500 |
| ទិន្នន័យរបស់ MaFReDI | 114,084[4] | 83,800 |
| ភាពខុសគ្នា | **-8.9%** | **-33.3%** |

ខណៈ ដែលរបាយការណ៍ FCMAS ត្រូវបានអនុម័តដោយរដ្ឋបាលជលផល និងបោះពុម្ពនៅលើគេហទំព័ររបស់រដ្ឋបាលជលផល មានការរិះគន់ច្រើនលើវិធីសាស្រ្តនិងការគ្របដណ្តប់នៃ FCMAS ក្នុងបណ្តារដ្ឋបាលជលផល។ មួយផ្នែកនេះគឺជាលទ្ធផលនៃតម្លាភាពអំពីរបៀបប្រមូលទិន្នន័យនិងរបៀប ដែលការសន្មត់ជាក់លាក់លើសមត្ថភាពនេសាទ ទូកនេសាទសកម្ម និងចំនួនទូនេសាទសរុប ជាទិន្នន័យចាំបាច់ដើម្បីគណនាការប៉ាន់ប្រមាណផលនេសាទសរុប។ ជាមួយនឹងការផ្តោតសំខាន់លើការប៉ាន់ប្រមាណផលនេសាទសរុបនិងភាពមិនស្របគ្នាជាមួយនឹងការប៉ាន់ប្រមាណផលនេសាទសរុបជាផ្លូវការ អ្នកនៅខាងក្រៅ MaFReDI មានទំនោរចាត់ទុកលទ្ធផលវាយតម្លៃទាំងនេះថាមិនត្រឹមត្រូវ ឬមិនតំណាងអោយផលនេសាទ។ លើសពីនេះ បើទោះបីជារបាយការណ៍ទាំងអស់ត្រូវបានបោះពុម្ព និងមានជាភាសាអង់គ្លេសនិងភាសាខ្មែរក៏ដោយ អត្ថិភាពនៃរបាយការណ៍នេះមិនបានទូលំទូលាយនោះទេ។ ដូចនេះ កង្វះការយល់ដឹងនិងការទទួលយកលទ្ធផល FCMAS បានធ្វើអោយប៉ះពាល់ដល់ការប្រើប្រាស់ទិន្នន័យ ដែលអាចយកទៅប្រើប្រាស់បាន ក្រៅពីការប៉ាន់ប្រមាណផលនេសាទសរុប មានទិន្នន័យល្អៗអំពីផលចាប់តាមប្រភេទ ការប្រើប្រាស់ឧបករណ៍ សមត្ថភាពនេសាទ និង CPUE។

ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ ការវាយតម្លៃ និងការសម្រេចចិត្តកាន់តែប្រសើរដល់អន្តរាគមន៍គ្រប់គ្រងនិងការធ្វើឱ្យលទ្ធផលកាន់តែអាចទទួលយកបាន MaFReDI យល់ស្របលើភាពចាំបាច់ក្នុងការកែតម្រូវលើការអនុវត្ត FCMAS ចាប់ពីឆ្នាំ២០២៤ តទៅ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពី FAO CAPFISH។

អនុសាសន៍ផ្តល់ជូនខាងក្រោមមានការលំបាក់ដល់រដ្ឋបាលជលផល MaFReDI និង ខណ្ឌរដ្ឋបាលជលផល ក្រោមស្ថានភាពថវិកានិងមន្ត្រីបច្ចុប្បន្ន ប៉ុន្តែអនុសាសន៍ទាំងនេះគួរតែត្រូវបានពិចារណាសម្រាប់ការប្រមូលទិន្នន័យរយៈពេលវែង ដូចជាយុទ្ធសាស្រ្តជាតិប្រមូលទិន្នន័យសម្រាប់ជលផលនិងវារីវប្បកម្ម (NSDFA) ដែលរដ្ឋបាលជលផលគ្រោងនឹងអភិវឌ្ឍក្នុងអំឡុងឆ្នាំ២០២៤។ ការពិភាក្សាជាក់លាក់អំពីរបៀបកែលម្អស្ថិតិជលផលកម្ពុជាគឺចាំបាច់ ហើយចាំបាច់ត្រូវបង្កើតការអភិវឌ្ឍផែនការរយៈពេលវែងសម្រាប់ការប្រមូលទិន្នន័យ រួមបញ្ចូលជាមួយតម្រូវការព័ត៌មានសម្រាប់ការអនុវត្តផែនការគ្រប់គ្រងជលផលសមុទ្រ (MFMP) និងការរៀបចំឯកសារគោលនយោបាយ។ ចំនុចទាំងនេះត្រូវលើកថវិកាគាំទ្រសម្រាប់ការប្រមូលទិន្នន័យស្ថិតិ និងការធ្វើវិមជ្ឈការក្រោមការជម្រុញបច្ចុប្បន្ននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឌីជីថលនៃទិន្នន័យនិងព័ត៌មាន និងការសម្រេចចិត្តផ្អែកលើភស្តុតាង។

---

[4] នេះគឺជាការប៉ាន់ប្រមាណផលចាប់សរុបដែលបានធ្វើបច្ចុប្បន្នភាព ដោយប្រើវិធីសាស្រ្តស្តង់ដារដូច ដែលបានណែនាំដោយ FAO (ដូចដែលបានប្រើក្នុងរបាយការណ៍នេះ) លទ្ធផលនេះមិនទាន់ត្រូវបានគាំទ្រដោយថ្នាក់ដឹកនាំនៃរដ្ឋបាលជលផលនៅឡើយ និងខុសពីការប៉ាន់ស្មានផលចាប់សរុបដែលបានបោះពុម្ពដំបូងសម្រាប់ឆ្នាំ២០២២ (២៣២.៧៥៥ តោន)។

ដោយសារមិនតម្រូវអោយ MaFReDI បន្តប្រមូលទិន្នន័យ FCMAS ក្នុងការអនុវត្តនៅឆ្នាំ២០២៤ ប្រសិនមានការសម្រេចចិត្តបន្តអនុវត្តការស្ទង់មតិ FAO CAPFISH ណែនាំអោយមានការផ្លាស់ប្តូរមួយចំនួនរួមមានការអនុវត្តនិងការរាយការណ៍ដូចមានរៀបរាប់ខាងក្រោម។ ការណែនាំទាំងអស់នេះគួរតែត្រូវបានបង្ហាញនិងពិភាក្សាក្នុងសិក្ខាសាលាប្រចាំឆ្នាំរបស់ MaFReDI នៅដើមឆ្នាំ២០២៤ ដោយមានតំណាងមកពីរដ្ឋបាលជលផលនិងខណ្ឌរដ្ឋបាលជលផល នៅមុនពេលចាប់ផ្តើមប្រមូលទិន្នន័យ។ វាចាំបាច់ក្នុងការយល់ច្បាស់អំពីគោលបំណងនៃការបន្តការប្រមូលទិន្នន័យផលចាប់និងសមត្ថភាពនេសាទបច្ចុប្បន្ននៅកន្លែងឡើងផលនេសាទ និងផលប្រយោជន៍ដល់ទិន្នន័យគោលមានស្រាប់នៃការអនុវត្ត FCMAS ពីការប្រមូលទិន្នន័យមួយឆ្នាំទៀត។

របាយណ៍នេះផ្តល់អនុសាសន៍អោយមានការពិគ្រោះជាមួយទាំងថ្នាក់គ្រប់គ្រងនៃរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល ក្នុងអំឡុងពេលសិក្ខាសាលាប្រចាំឆ្នាំ ដើម្បីកំណត់ថាតើព័ត៌មានណាដែលត្រូវការ និងវិធីល្អបំផុតដើម្បីទទួលបានព័ត៌មានទាំងនោះ ធ្វើឱ្យលទ្ធផលនៃ FCMAS កាន់តែពាក់ព័ន្ធដល់ការប្រើប្រាស់សម្រាប់ខណ្ឌរដ្ឋបាលជលផលនិងរដ្ឋបាលជលផលសម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃនៃអន្តរាគមន៍គ្រប់គ្រងក្រោម MFMP។

**ព័ត៌មានសំខាន់ៗ៖**

- ផលចាប់ក្នុង១ឯកតាកម្លាំងនេសាទ (CPUE) និងសមត្ថភាពនេសាទ (តាមឧបករណ៍និងទីតាំងដាក់លាក់)
- ទូកនេសាទសកម្ម
- ផលចាប់តាមប្រភេទ/តម្លៃ/ថ្លៃ
- ផលនេសាទសរុបប៉ានប្រមាណថ្នាក់ជាតិ/ថ្នាក់ខេត្តប្រចាំខែ

**ព័ត៌មានបន្ទាប់បន្សំផ្សេងទៀត៖**

- ការប្រើប្រាស់ផលនេសាទ
- ថ្លៃចំណាយ-ប្រាក់ចំណូល-ប្រាក់ចំណេញ

ទោះសម្រេចចិត្តបែបណាក៏ដោយ មានអនុសាសន៍មួយចំនួនផ្តល់ជូនរដ្ឋបាលជលផលក្នុងការរៀបចំស្ថិតិជលផលប្រចាំឆ្នាំ៖

- ពិចារណាពីរបៀបដែលលទ្ធផលពី FCMAS អាចត្រូវបានប្រើសម្រាប់បំពេញបន្ថែមដល់ស្ថិតិជលផលដែលបានបោះពុម្ពផ្សាយសម្រាប់ខេត្តជាប់មាត់សមុទ្រ
- ប្រើប្រាស់ទិន្នន័យ ដែលមានស្រាប់កាន់តែប្រសើរ ឧ. ប្រើទិន្នន័យពី VMS និង SMART សម្រាប់ការផ្ទៀងផ្ទាត់សមត្ថភាពនេសាទនិងទីតាំងនេសាទ ដើម្បីបកស្រាយទិន្នន័យទទួលបានពី FCMAS
- អនុវត្តការប្រមូលទិន្នន័យតាមសៀវភៅបន្ទុកដែលរៀបចំឡើងវិញ សម្រាប់ទូកនេសាទមានអាជ្ញាប័ណ្ណ ដើម្បីបំពេញបន្ថែមដល់ទិន្នន័យ FCMAS
- ផ្ទៀងផ្ទាត់ទិន្នន័យដោយផ្អែកលើកំណត់ត្រាពាណិជ្ជកម្ម/ការនាំចេញ ទិន្នន័យសេដ្ឋកិច្ចសង្គម (NIS) និងទិន្នន័យ NCDD ព្រមទាំងការស្ទង់មតិផ្ទៀងផ្ទាត់ទាក់ទងនឹងសមាសភាពប្រភេទ/ផលចាប់សរុប និង
- បង្កើតយុទ្ធសាស្ត្រជាមួយនាយកដ្ឋានផែនកសារនៃរដ្ឋបាលជលផល (DPFIC) លើការប្រគល់ការអនុវត្ត FCMAS ឬវិធីសាស្ត្រប្រមូលទិន្នន័យ ដែលបានរៀបចំឡើងវិញ ដោយផ្អែកលើមេរៀនទទួលបានពីការអនុវត្ត FCMAS ដល់ខណ្ឌរដ្ឋបាលជលផល ព្រមទាំងការកែលម្អការធ្វើរបាយការណ៍ទៅមន្ទីរកសិកម្មនិងរដ្ឋបាលជលផលសម្រាប់ការរៀបចំស្ថិតិជលផលជាតិ។

លើសពីនេះ FAO CAPFISH ក្រោមកិច្ចសហការជាមួយ MaFReDI ផ្តល់អនុសាសន៍ដូចខាងក្រោម ដើម្បីពិភាក្សា និងទទួលការឯកភាពពីរដ្ឋបាលជលផលនិងខណ្ឌរដ្ឋបាលជលផលនៅដើមឆ្នាំ២០២៤ ដូចខាងក្រោម៖

១. ផ្តោតជាចាំបាច់លើការប្រមូលទិន្នន័យ ដែលគាំទ្រដល់អាទិភាពនៃការស្រាវជ្រាវ (ឧ. ប្រាក់ចំណូល/ថ្លៃដើម ទិន្នន័យសេដ្ឋកិច្ច-សង្គម ការវាយតម្លៃស្តុក ការសិក្សាកូនត្រី សារៈសំខាន់នៃជម្រកសំខាន់ៗ) មិនត្រឹមតែប្រមូលទិន្នន័យតាមដានផលចាប់តាមទម្លាប់ប៉ុណ្ណោះទេ។

២. ដោយការប្រើប្រាស់លទ្ធផល FCMAS នៅមានតិចតួចនៅឡើយ ចាំបាច់ត្រូវស្វែងរកមធ្យោបាយទំនាក់ទំនង និងបង្ហាញវិធីសាស្ត្រនិងរបកគំហើញទៅកាន់រដ្ឋបាលជលផល ថ្នាក់ដឹកនាំនៃរដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អោយកាន់តែទូលំទូលាយ រួមមាន៖

   ក. សេចក្តីសង្ខេបលទ្ធផលខ្លីៗជូនលោកប្រធានរដ្ឋបាលជលផលនិងលេខាធិការអចិន្ត្រៃយ៍។

   ខ. សិក្ខាសាលាបច្ចេកទេសនិងការបង្ហាញលទ្ធផលនៅក្នុងអង្គប្រជុំក្រុមការងារបច្ចេកទេសស្តីពីជលផល។

   គ. ការរៀបចំអត្ថបទផ្សាយបែបវិទ្យាសាស្រ្ត ដោយផ្អែកលើសំណុំទិន្នន័យ។

   ឃ. ការបោះផ្សាយសំណុំទិន្នន័យជាច្បាប់ចម្លង ដែលបានសម្អាតនិងធ្វើអនាមិក (ដើម្បីការពារឯកជនភាពរបស់អ្នកនេសាទ និងម្ចាស់ទូកនេសាទ) នៅលើប្រព័ន្ធគ្រប់គ្រងព័ត៌មានជលផល (FIMS)។

   ង. បង្កើតអោយមានការបង្ហាញទិន្នន័យសង្ខេបលើ FIMS ដែលអាចអោយអ្នកប្រើប្រាស់ទាញយកបាន

   ច. រៀបចំនិងចែកចាយរបាយការណ៍ស្ថិតិប្រចាំខែ នៅក្នុងខែបន្ទាប់ ក្រោយពីការប្រមូលទិន្នន័យ និង

   ឆ. ការរៀបចំរបាយការណ៍ត្រួតពិនិត្យឡើងវិញលើលទ្ធផលនៃការអង្កេតតាមដានជលផលសមុទ្រតាមបែបវិទ្យាសាស្រ្តសម្រាប់ផលចាប់និងសមត្ថភាពនេសាទ សម្រាប់ឆ្នាំ២០២១-២០២៤។

៣) ដាក់បញ្ចូលមតិកែលម្អទាំងឡាយដល់វិធីសាស្រ្ត FCMAS ទៅក្នុងសៀវភៅណែនាំ ដែលបានធ្វើបច្ចុប្បន្នភាពដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការកែតម្រូវវិធីសាស្រ្ត ដែលបានព្រមព្រៀងគ្នាសម្រាប់ឆ្នាំ២០២៤។

៤) ដោយពិនិត្យមើលលទ្ធផលនៅឆ្នាំ២០២៣ ដើម្បីគាំទ្រការប៉ាន់ប្រមាណផលនេសាទប្រចាំខែថ្នាក់ជាតិ ការស្ទង់មតិត្រូវការប្រើសំណាកចៃដន្យ ដែលញែកកំណត់ជាក់លាក់ជាងមុន ដើម្បីបង្កើនការគ្របដណ្តប់ទូកអួនអូសធំៗ (១៨-២៤ម៉ែត្រ) ដែលមានការអង្កេតត្រឹមតែ ២ប៉ុណ្ណោះក្នុងឆ្នាំ២០២៣។ ទូកនសាទខ្នាតធំ ដែលកំណត់ត្រាអង្កេតចំនួន ៤ដង ប៉ុណ្ណោះ ខណៈដែលទូកនេសាទខ្នាតមធ្យម មិនមែនជាទូកអួនអូស ត្រូវការការគ្របដណ្តប់កាន់តែប្រសើរ (ឬធ្វើការញែកសំណាក)។ ការគ្របដណ្តប់នេះមិនតំណាងតាមចំនួនទូកនេសាទក្នុងប្រភេទនីមួយៗ យោងតាមជំរឿននាវានេសាទឆ្នាំ២០១៨ ឬសារៈសំខាន់ទៅនឹងជលផល ដែលនាំឱ្យមានបញ្ហាជាមួយនឹងការប្រើប្រាស់ទិន្នន័យនេះសម្រាប់ធ្វើការប៉ាន់ប្រមាណផលនេសាទសរុប។ ផ្អែកលើទិន្នន័យឆ្នាំ២០២២-២៣ ទំហំសំណាកគោលដៅប្រចាំខែគឺស្ថិតនៅចន្លោះ ±១៨០-៣៦០ សំណាកបច្ចុប្បន្នចំនួន ២២៤ (តារាង ១២)។

តារាងទី១២. គោលដៅសំណាកគំរូប្រចាំខែ ដែលណែនាំជូន អាស្រ័យលើការប្រែប្រួលអង្កេតនៅឆ្នាំ២០២២-២៣

| ថ្នាក់ទូក-ឧបករណ៍នេសាទ | ការឡើងផលនេសាទកត់ត្រាប្រចាំខែកឆ្នាំ២០២៣ | ទិន្នផលនេសាទតាមទូកនេសាទប្រចាំខែ ឆ្នាំ២០២៣ | ការរួមចំណែកផលនេសាទសរុប (%) | ទំហំសំណាកអប្បរមាប្រចាំខែ | ទំហំសំណាកអប្បរមាប្រចាំខែ ល្អបំផុត |
|---|---|---|---|---|---|
| ខ្នាតតូច <៦ម | <1 | 27.5 | 0.3% | | |
| ខ្នាតតូច ៦-<១២ម | 49 | 449.0 | 17.1% | 30 | 45 |
| អួនអូស ៦-<១២ម | 60 | 1,169.4 | 16.0% | 35 | 55 |
| អួនអូស ១២-១៨ម | 37 | 8,725.9 | 42.4% | 12 | 20 |
| អួនអូស ១៨-<២៤ម | <1 | 3,533.3 | 2.2% | **25** | **40** |
| ឧបករណ៍ផ្សេងទៀត ១២-១៨ម | 68 | 754.8 | 17.2% | 70 | 160 |
| ឧបករណ៍ផ្សេងទៀត ១៨-<២៤ម | 7 | 2,299.0 | 1.8% | 10 | 40 |
| ខ្នាតធំ លើស ២៤ម | <1 | 23,462.5 | 3.0% | **1** | **3** |
| **ទំហំសំណាកសរុប** | **224** | | | **183** | **363** |

គោលដៅរបស់ FCMAS គឺធ្វើយ៉ាងណាធ្វើឱ្យការប៉ាន់ប្រមាណប្រចាំខែកាន់តែជឿទុកចិត្តបាន ដូចនេះការស្ទង់មតិមិនអាចពឹងផ្អែកលើគំរូចៃដន្យដូច ដែលត្រូវបានអនុវត្តនៅអំឡុងឆ្នាំ២០២១-២០២៣ ទៀតទេ ព្រោះនេះសំណាកគំរូមានច្រើនលើប្រភេទនៃទូកនេសាទ-ឧបករណ៍ខ្លះ និងតិចតួចលើប្រភេទនៃទូកនេសាទ-ឧបករណ៍ ផ្សេងទៀត៖

ក. ចាំបាច់ត្រូវញែកសំណាកលំដាប់លំនិងដោយចៃចន្យ ដោយផ្អែកលើលំនាំការឡើងផលនេសាទ ដែលបានសង្កេតកន្លងទៅ និងការប្រែប្រួលរវាងប្រភេទទូកនេសាទ-ឧបករណ៍ ដោយកំណត់គោលដៅសំណាកគំរូសម្រាប់ប្រភេទទូកនេសាទ-ឧបករណ៍ ដែលបានឯកភាពគ្នា នៅតាមកន្លែងឡើងផលនេសាទនីមួយៗ និងធ្វើការបែងចែកសារជាថ្មីនូវសមត្ថភាពការងារសម្រាប់ការស្ទង់មតិ

ខ. កែសម្រួលទំហំគំរូគោលដៅ (ចំនួនអង្កេតការឡើងផលនេសាទ) អាស្រ័យលើការប្រែប្រួល ដែលបានសង្កេតឃើញ និងសារៈសំខាន់អំពីព័ត៌មានអំពីផលផល និង

គ. ធ្វើការកែប្រែ ឬផ្លាស់ប្តូរទីតាំងឡើងផលនេសាទដើម្បីបង្កើនភាពតំណាងនៃសំណាក។

ទំហំគំរូប្រចាំខែអប្បបរមា ដែលមានរួមបញ្ចូលក្នុងតារាងទី១២ តំណាងឱ្យគំរូចៃដន្យ ដែលត្រូវបានញែកពេញលេញក្នុងបណ្តាទីតាំងឡើងផលនេសាទគោលដៅទាំងអស់ ទទ្ទឹមនឹងជម្រើសទំហំគំរូប្រចាំខែខ្ពស់បំផុតអាចឱ្យមានការប៉ាន់ប្រមាណប្រចាំខែនៅថ្នាក់ខេត្តលើសូចនាករសំខាន់ៗ (ផលនេសាទ សមត្ថភាពនេសាទ និង CPUE)។

៥) កែលម្អការប៉ាន់ប្រមាណសមត្ថភាពនេសាទ (ថ្ងៃធ្វើនេសាទ) ដោយរួមបញ្ចូលសំណួរបន្ថែមអំពីការឡើងផលនេសាទក្នុងជើងនេសាទច្រើនថ្ងៃ៖

ក. ចំនួនថ្ងៃធ្វើនេសាទ/ជើងនេសាទ (ថ្ងៃប្រតិបត្តិការនេសាទ) សម្រាប់ការឡើងផលនេសាទបច្ចុប្បន្ន

ខ. រយៈពេលសម្រាក់/ផ្អាកជាធម្មតា រវាងជើងដំណើរ (ចំនួនថ្ងៃ)

៦) គាំទ្រដល់សកម្មភាពធ្វើជំរឿន/ការស្ទង់មតិលើទូកនេសាទសមុទ្រឆ្នាំ២០២៤ ដើម្បីធ្វើអោយការប៉ាន់ប្រមាណផលនេសាទសរុបកាន់តែសុក្រិត។

៧) ផ្នែកនៃផលនេសាទត្រូវបានរួមបញ្ចូលនៅក្នុងក្រុម ដែលមានច្រើនប្រភេទបញ្ចូលគ្នា ដូចជាក្រុមប្រភេទត្រីចំរុះ ក្រុមត្រីជី ឬក្រុមផ្សេងៗ ដែលក្រុមប្រភេទទាំងនេះរួមចំណែក ១២៧.៦២១ គីឡូក្រាម (១៨,៩%) ទៅនឹងផលនេសាទរាយការណ៍សរុប បើចំនួនទាំងនេះដាក់រួមបញ្ចូលគ្នាជាមួយក្រុមប្រភេទ ដែលមានប្រមូលផ្តុំប្រភេទខ្ពស់ផ្សេងទៀត ឧ. ងាវចំរុះ មឹកពីងពាង/មឹកចំរុះ និងត្រីឈាម ក្រុមប្រភេទផ្សេងទៀតបានរួមចំណែកជាង ៣១% នៃផលចាប់រាយការណ៍សរុប ហើយទិន្នន័យនេះរារាំងដល់ការវិភាគលម្អិតបន្ថែមទៀត ដើម្បីវាយតម្លៃស្ថានភាព និងនិន្នាការនៃជលផល។ ដូច្នេះជាការចាំបាច់ណាស់ក្នុងការកែលម្អអោយមានព័ត៌មានលម្អិតអំពីប្រភេទដោយៈ

ក. ធ្វើការបន្ថែមប្រភេទ ដែលមិនមានទៅក្នុងបញ្ជីប្រភេទបច្ចុប្បន្ន

ខ. ធ្វើការភ្ជាប់ប្រភេទនិងលេខកូដសម្គាល់ទៅលេខកូដស្តង់ដារអន្តរជាតិ ដែលប្រើដោយ FAO និង SEAFDEC ដោយប្រើបញ្ជីប្រភេទ FFI/MCC ជាមូលដ្ឋាន

គ. ធ្វើស្តង់ដារឈ្មោះខ្មែរ ដែលបានបញ្ចូលក្នុងកម្មវិធីកូបូ ដើម្បីកាត់បន្ថយកំហុសអក្ខរាវិរុទ្ធ និងធ្វើអោយការភ្ជាប់ជាមួយប្រភេទនិងក្រុមប្រភេទកាន់តែល្អប្រសើរ

ឃ. ពិចារណាលើការជ្រើសរើសសំណាកលើប្រភេទជាក់លាក់សម្រាប់ក្រុមមួយចំនួន ដែលមានប្រមូលផ្តុំប្រភេទច្រើនខ្លាំង ដើម្បីអាចងាយស្រួលក្នុងការវាយតម្លៃសមាសភាពប្រភេទ (ប្រែប្រួលតាមរដូវ)។

៨) ការវិភាគរហ័សនៃសមាសភាពប្រភេទនៃការនេសាទដោយទូកអួនអូស បង្ហាញថាទូកអួនអូសផ្តោតសំខាន់លើប្រភេទ ដែលមានតម្លៃទាប។ ប្រាក់ចំណេញពីការនេសាទទំនងជាបានមកពីក្រុមមឹក ពពួកបង្គាគ្រប់ប្រភេទ និងការនេសាទបានប្រភេទដែលមានតម្លៃខ្ពស់ម្តងម្កាល។ ការនេសាទ ដែលចាប់បានភាគច្រើនជាប្រភេទមានតម្លៃទាប ប្រហែលជាមិនមានប្រសិទ្ធភាពចំណាយ ឬក៏មិនមាននិរន្តរភាពសេដ្ឋកិច្ច ហើយ MaFReDI គួរតែស្វែងយល់អំពីចំនុចនេះឱ្យបានលម្អិតបន្ថែមទៀត ដើម្បីជាការរួមចំណែកក្នុងការជូនដំណឹងដល់ជលផលសមុទ្រ អំពីអន្តរាគមន៍គ្រប់គ្រង ដែលអាចអនុវត្តបាន ដើម្បីបង្កើនតម្លៃនិងប្រាក់ចំណេញដល់នេសាទសមុទ្រ។

៩) ដើម្បីធ្វើអោយប្រសើរដល់ការប្រៀបធៀបនិងការធ្វើរបាយការណ៍ទិន្នន័យលើការប្រើប្រាស់ឧបករណ៍ (សមត្ថភាពនេសាទ) និង CPUE ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពនិងធ្វើស្តង់ដារបញ្ជីឧបករណ៍នេសាទសមុទ្រ ព័ត៌មានទាំងនេះក៏សំខាន់ផងដែរសម្រាប់ប្រើប្រាស់ក្នុងរបាយការណ៍ស្ថិតិជាតិ និងនៅក្នុងកម្មវិធីពាក់ព័ន្ធដូចជាកម្មវិធី SMART VMS អាជ្ញាប័ណ្ណនេសាទ និងជំរឿនទូកនេសាទសមុទ្រ នៅរដ្ឋបាលជលផលៈ

ក. បន្ថែមប្រភេទឧបករណ៍និងលេខកូដស្របតាមចំណាត់ថ្នាក់ស្តង់ដារស្ថិតិនៃឧបករណ៍នេសាទ (ISSCFG) ដូចដែលបានប្រើដោយ FAO

ខ. ប្រមូលប្រភេទឧបករណ៍លម្អិតបន្ថែមអំពីទូកអួនអូស ឧ. pelagic, mid-water, otter board, pair- and beam-trawlers ដើម្បីវាយតម្លៃផលនេសាទបានប្រសើរជាងមុន ប្រភេទចាប់បាន (គោលដៅ) សមត្ថភាពនេសាទ និង CPUE៖

អួនអូសស្រទាប់លើ (**Pelagic trawlers**) ចែកចេញជា៖

i. Mid-water/fly trawl (អួនហោះ) code TSP

ii. Semi-pelagic trawl for fish (អួនអូសត្រី) code TM

iii. Midwater otter trawls for squid (អួនអូសមឹក) code OTM

អួនអូសស្រទាប់បាត (Bottom trawlers) ចែកចេញជា៖

iv. Beam trawl (អួនអូសច្រើនចូរ or អួនឡែកខិ) code TBB

v. Bottom trawls for shrimp (អួនអូស/មងខាវ) code TBS

គ. ធ្វើការពិនិត្យនិងបន្សុីគ្នាការចាត់ថ្នាក់និងឈ្មោះខ្មែរនិងអង់គ្លេស សម្រាប់ប្រើធ្វើបច្ចុប្បន្នភាពបញ្ជីឧបករណ៍ (drop-down list) សម្រាប់ជ្រើសរើសប្រភេទឧបករណ៍/ឈ្មោះ ប្រើក្នុងកម្មវិធីកូបូ

ឃ. ធ្វើការដកចេញទាំងស្រុងនូវរាល់ឧបករណ៍មិនមានបញ្ជាក់អត្តសញ្ញាណនៅក្នុងទិន្នន័យ (មាន ២,២% នៃទម្ងន់ឡើងផលនេសាទរាយការណ៍សរុបនៅឆ្នាំ២០២៣)។ កំណត់ត្រាមិនមានជ្រើសរើសឈ្មោះឧបករណ៍នេសាទ ចាំបាច់ត្រូវកំណត់សម្គាល់ក្នុងអំឡុងពេលប្រមូល/បញ្ចូលទិន្នន័យ ដើម្បីធ្វើការសួរសំណួរបញ្ជាក់បន្ថែម (ឬអ្នកនេសាទអាចទាក់ទងតាមទូរស័ព្ទក្រោយការសម្ភាសន៍) ប្រសិនបើគ្មានការកត់ត្រាឧបករណ៍។

១០) ប្រភពនៃទិន្នន័យ (កំណត់ត្រាម្ចាស់ទូក/ពាណិជ្ជករ ឬការសម្ភាសន៍តាមបែបរំលឹកឡើងវិញ) មិនត្រូវបានកត់ត្រាត្រឹមត្រូវនៅឡើយ តាមរយៈលទ្ធផលពីការអង្កេតបង្ហាញថាមានការឡើងផលនេសាទចំនួន ៥ ប៉ុណ្ណោះ (0,៣%) គឺផ្អែកលើកំណត់ត្រារបស់អ្នកនេសាទ ពាណិជ្ជករ ឬម្ចាស់ទូក។ លទ្ធផលនេះមានន័យថាការឡើងផលនេសាទស្ទើរតែទាំងអស់គឺផ្អែកលើការសម្ភាសន៍បែបរំលឹកឡើងវិញ។ ប្រភពទិន្នន័យបែបនេះបង្កើតអោយមានភាពមិនច្បាស់លាស់អំពីទម្ងន់នៃប្រភេទ ដែលត្រូវបានកត់ត្រា។ ដោយសារតែផលនេសាទពីសមុទ្រស្ទើរតែទាំងអស់ត្រូវបានលក់ គេរំពឹងថាម្ចាស់ទូក មេដៃ/តៃកុងទូក អ្នកនេសាទ/កម្មករ និងពាណិជ្ជករ/ឈ្មួញ នឹងរក្សាកំណត់ត្រានៃប្រតិបត្តិការនេសាទ សមាមាត្រនៃផលនេសាទ ដែលទិន្នន័យបែបកំណត់ត្រាជាលាយលក្ខណ៍អក្សរ ឬវិក័យបត្រលក់អាចខ្ពស់ជាងការសម្ភាសន៍។ ជាមួយនឹងការកែប្រែមួយចំនួនលើវិធីសាស្ត្រប្រមូលទិន្នន័យតាមប្រភេទទូកនេសាទ-ឧបករណ៍ ដែលរំពឹងថានឹងទទួលបានកំណត់ត្រាលក់ផលនេសាទ នាំអោយការប្រមូលទិន្នន័យប្រសើរនិងមានភាពសុក្រឹតជាងមុន។ ខណៈដែលការឡើងផលនេសាទក្រៅផ្លូវការកាន់តែច្រើន ការនេសាទខ្នាតតូចនៅតែអាចគ្របដណ្តប់ដោយការស្ទង់មតិឡើងវិញនៅកន្លែងឡើងផលនេសាទ រីឯការនេសាទខ្នាតមធ្យមអាចគ្របដណ្តប់កាន់តែប្រើសើរដោយការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (អ្នកនេសាទ/កម្មករនេសាទ មេដៃ/តៃកុងទូក និងម្ចាស់ទូក) នៅតាមផ្ទះរបស់ពួកគេ។

១១) ខណៈដែលទិន្នន័យសេដ្ឋកិច្ច-សង្គមផ្តល់នូវព័ត៌មានអំពីផលចំណេញនៃការធ្វើនេសាទ ជាអនុសាសន៍ ស្ទង់មតិអំពីសូចនាករសេដ្ឋកិច្ច-សង្គម អាចអនុវត្តប្រចាំត្រីមាស។ ការផ្លាស់ប្តូរបន្ថែមមួយចំនួនអាចត្រូវធ្វើឡើងផ្អែកលើការវិភាគស៊ីជម្រៅបន្ថែមទៀតនិងការពិនិត្យឡើងវិញនៃសេចក្តីតម្រូវសម្រាប់ MFMP។

១២) ត្រូវធ្វើការពិចារណាលើការអនុវត្តការស្ទង់មតិផ្ទៀងផ្ទាត់បន្ថែម ដើម្បីកំណត់ទាំងសមាសភាពប្រភេទនិងផលនេសាទតាមប្រភេទ ដោយប្រើសំណាករង ដែលទិញពីអ្នកនេសាទ ឬម្ចាស់ទូកនេសាទ ពីការឡើងផលនេសាទដែលបានជ្រើសរើសដោយចៃដន្យតាមថ្នាក់ទូក-ឧបករណ៍នេសាទ។

១៣) ធ្វើការពិនិត្យឡើងវិញលើការផ្ទៀងផ្ទាត់អំពីសុពលភាពទិន្នន័យផលចាប់ សមត្ថភាពនេសាទ និងតម្លៃ បញ្ចូលក្នុងកម្មវិធីកូបូ ដើម្បីកាត់បន្ថយការវាយអក្សរនិងព័ត៌មានមិនពាក់ព័ន្ធ ដែលសម្រួលដល់ការសម្អាតទិន្នន័យ។

១៤) ធ្វើការពង្រឹងការផ្សាភ្ជាប់ទៅនឹងការកែច្នៃផល ផលិតផលជលផល (ការប្រើផលជលផល) ទាំងតាមរយៈការកែតម្រូវ FCMAS បច្ចុប្បន្ន និងការស្រាវជ្រាវបន្ថែម ជាពិសេសសម្រាប់ត្រីជី ត្រីចំរុះ/ផ្សេងៗ និងការបោះចោលផលនេសាទ។

ក. នៅក្នុង FCMAS ប្រសិនបើមានកំណត់ត្រាអំពីត្រីសំរាម ឬត្រីចំរុះ/ផ្សេងៗ ប្រភេទនិងការប្រើប្រាស់គួរតែបញ្ជាក់បន្ថែមថាត្រូវប្រើធ្វើអ្វីខ្លះ៖ ត្រីម្សៅ ចំណីសម្រាប់វារីវប្បកម្ម (ត្រីចិញ្ចឹមក្នុងបែរ) មនុស្សបរិភោគ (ស្រស់ឬកែច្នៃ) ចំណីសម្រាប់បសុសត្វ ធ្វើជី ឬការប្រើប្រាស់ផ្សេងទៀត

ខ. ធ្វើការកែលម្អលើទិន្នន័យស្តីពីសមាសភាពប្រភេទសអំពី 'ត្រីជី' និងក្រុមប្រភេទ ជាពិសេស ក្រុមប្រភេទត្រីចំរុះ/ផ្សេងៗ ដែលរួមចំណែករហូតដល់ ១៣% នៃផលនេសាទរាយការណ៍សរុប តាមរយៈការធ្វើអង្កេតលើសំណាកគំរូតាមក្រុមប្រភេទបន្ថែម និងការវិភាគលើការឡើងផលនេសាទ ដែលបានជ្រើសរើស ជាប្រធានបទស្រាវជ្រាវ ដោយសហការជាមួយសាកលវិទ្យាល័យ និងជាមួយខណ្ឌរដ្ឋបាលជលផល និង

គ. ទិន្នន័យអំពីផលនេសាទបោះបង់ចោលមានតំណាងតិចតួចខ្លាំង (តិចជាង ០,០៧% នៃផលនេសាទរាយការណ៍សរុប) ទិន្នន័យនេះតំណាងឱ្យតែសមាមាត្រដ៏តូចនៃផលនេសាទបោះបង់ចោលពិតប្រាកដ ទិន្នន័យអំពីផលនេសាទបោះបង់ចោលគួរតែត្រូវបានស្វែងយល់បន្ថែមតាមរយៈការស្រាវជ្រាវ ដោយប្រើការកត់ត្រាសៀវភៅបន្ទុកដោយស្ម័គ្រចិត្ត ឬការរាយការណ៍ជាអនាមិក និង/ឬតាមរយៈកម្មវិធីសង្កេតជាក់លាក់។

១៥) អនុវត្តការស្ទង់មតិអំពីនេសាទសកម្ម ដូចដែលបានណែនាំដោយ FAO CAPFISH ដោយគ្របដណ្តប់លើគំរូថៃជន្យនៃប្រភេទនាវា-ឧបករណ៍នេសាទសំខាន់ៗ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៤

ហត្ថលេខា

លោក ជា ផារិទ្ធ

បានឃើញ

ថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ សីហា ឆ្នាំ២០២៤

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល និងជាប្រធានគម្រោង CAPFISH-Capture

ពុំ សុធា

ឧបសម្ព័ន្ធទី១. សមាសភាគផលនេសាទ តាមក្រុមប្រភេទគ្រប់ការឡើងផលនេសាទ តាមទម្ងន់និងតម្លៃ

| ក្រុមប្រភេទ | ទម្ងន់សរុប (គ.ក្រ) | ទម្ងន់សរុប% (គ.ក្រ) |
|---|---|---|
| ត្រី | 497,051.4 | 73.7% |
| សប្បីសត្វ | 60,499.7 | 9.0% |
| មឹក | 59,518.3 | 8.8% |
| បង្គា | 29,756.2 | 4.4% |
| ក្តាម | 16,847.7 | 2.5% |
| មិនមានបញ្ជាក់ប្រភេទ | 10,596.6 | 1.6% |
| បបែល | 414.3 | 0.06% |
| ឆ្លាម | 76.5 | 0.01% |
| **សរុបរួម** | **674,760.7** | |

| ក្រុមប្រភេទ | តម្លៃសរុប (១០០០ រៀល) | តម្លៃសរុប (%) |
|---|---|---|
| ត្រី | 915,927 | 32.8% |
| បបែល | 895,786 | 32.0% |
| ក្តាម | 439,512 | 15.7% |
| បង្គា | 399,109 | 14.3% |
| សប្បីសត្វ | 74,216 | 2.7% |
| មិនមានបញ្ជាក់ប្រភេទ | 67,570 | 2.4% |
| បបែល | 2,997 | 0.11% |
| ឆ្លាម | 535 | 0.02% |
| **សរុបរួម** | **2,795,653** | |
| | | |
| **ថ្លៃមធ្យម** | **4143** | |

ឧបសម្ព័ន្ធទី២. ការរួមចំណែកផលនេសាទតាមប្រភេទឧបករណ៍នេសាទនិងតាមខេត្ត

| ប្រភេទឧបករណ៍ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុបរួម (គ.ក្រ) |
|---|---|---|---|---|---|
| ទូកអួនអូស | 31.6% | 66.4% | 1.3% | 0.7% | 529,988.4 |
| មងត្រីកាម៉ុង | 25.5% | 49.5% | 25.0% | - | 52,255.0 |
| រនងខ្យងចាប់មឹកពីងពាង | 87.4% | 3.0% | - | 9.6% | 20,530.0 |
| មងត្រីផ្ទោង | - | 3.7% | 96.3% | - | 14,160.0 |
| មងត្រី | 9.9% | - | 86.7% | 3.4% | 9,267.2 |
| មងក្ដាម | 38.8% | 26.3% | - | 34.9% | 7,808.0 |
| លបត្រី | 91.3% | 8.7% | - | - | 6,895.0 |
| លបក្ដាម | 57.2% | - | 26.6% | 16.3% | 5,875.2 |
| មងបង្គា | 52.2% | 47.8% | - | - | 4,853.1 |
| លបត្រីម្រើមព្រះ | 26.8% | - | 0.7% | 72.5% | 1,792.8 |
| សន្ទូចអូសមឹកពីងពាង | 94.0% | 6.0% | - | - | 1,160.0 |
| សន្ទូចរនងចាប់មឹក | 100.0% | - | - | - | 1,080.0 |
| លបមឹក | 100.0% | - | - | - | 810.0 |
| អួនហ៊ុម | 100.0% | - | - | - | 810.0 |
| ឈិបយន្ត | 100.0% | - | - | - | 300.5 |
| មងត្រីក្បក | - | - | 91.9% | 8.1% | 135.0 |
| ឈ្នាងអូសគ្រែងឈាម | 100.0% | - | - | - | 79.0 |
| សន្ទូចត្រី | 34.9% | - | - | 65.1% | 63.0 |
| មងបីជាន់ចាប់បង្គា | - | - | 100.0% | - | 56.5 |
| សន្ទូចរនងចាប់ត្រី | 33.3% | - | 66.7% | - | 30.0 |
| មងត្រីកន្ទាំង | - | - | 100.0% | - | 30.0 |
| មងត្រីបេកា | - | - | - | 100.0% | 29.0 |
| សន្ទូចរនងបបែល | - | - | - | 100.0% | 13.0 |
| ឈិបរុញ | - | - | 100.0% | - | 9.5 |
| មិនមានបញ្ជាក់ឧបករណ៍ | 11.7% | 14.4% | 73.5% | 0.3% | 14,897.5 |
| ឧបករណ៍ចំរុះ (ច្រើនមុខចូលគ្នា) | 0.7% | - | 98.9% | 0.4% | 1,833.0 |
| **សរុបរួម** | **32.9%** | **57.4%** | **8.1%** | **1.7%** | **674,760.7** |

ឧបសម្ព័ន្ធទី៣. សមត្ថភាពផលចាប់ក្នុង១ឯកតា (CPUE) តាមខេត្ត

| ខេត្ត | ថ្នាក់នាវានេសាទ | ប្រភេទឧបករណ៍ | CPUE មធ្យម | N | SD | ε% |
|---|---|---|---|---|---|---|
| កំពត | ខ្នាតមធ្យម | មងត្រីផ្ទោង | 308.0 | 10 | 595.4 | **61.1%** |
| | | មងត្រីកាម៉ុង | 193.4 | 10 | 287.0 | **46.9%** |
| | | មងត្រី | 62.1 | 19 | 31.1 | 11.5% |
| | | ទូកអួនអូស | 42.8 | 161 | 14.5 | 2.7% |
| | | លបក្តាម | 20.9 | 56 | 6.3 | 4.0% |
| | ខ្នាតតូច | មងត្រី | 51.0 | 91 | 27.3 | 5.6% |
| | | មងត្រីក្បក | 41.3 | 3 | 6.0 | 8.4% |
| | | លបក្តាម | 15.8 | 22 | 5.1 | 6.9% |
| | | ឈិបរុញ | 4.8 | 2 | 1.1 | 15.8% |
| | | | | | | |
| កែប | ខ្នាតមធ្យម | រនងខ្សែចាប់មឹកពីងពាង | 54.3 | 9 | 41.6 | **25.5%** |
| | | លបក្តាម | 34.8 | 9 | 28.7 | **27.5%** |
| | | ទូកអួនអូស | 30.4 | 129 | 4.4 | 1.3% |
| | | មងក្តាម | 19.8 | 113 | 9.0 | 4.3% |
| | | លបត្រីម្រើមព្រះ | 19.6 | 18 | 11.3 | 13.6% |
| | | មងត្រី | 16.1 | 6 | 5.9 | 14.9% |
| | ខ្នាតតូច | សន្ទូចត្រី | 20.5 | 2 | 0.7 | 2.4% |
| | | មងត្រី | 16.5 | 13 | 9.7 | 16.4% |
| | | លបត្រីម្រើមព្រះ | 14.3 | 54 | 7.4 | 7.1% |
| | | មងក្តាម | 12.7 | 28 | 5.1 | 7.5% |
| | | លបក្តាម | 8.2 | 6 | 3.5 | 17.7% |
| | | | | | | |
| កោះកុង | ខ្នាតមធ្យម | ទូកអួនអូស | 221.5 | 109 | 427.9 | 18.5% |
| | | លបត្រី | 166.2 | 6 | 213.7 | **52.5%** |
| | | មងត្រីកាម៉ុង | 114.7 | 25 | 62.4 | 10.9% |
| | | រលងខ្សែចាប់មឹកពីងពាង | 57.5 | 54 | 38.3 | 9.1% |
| | | មងត្រី | 41.6 | 2 | 44.7 | **76.0%** |
| | | សន្ទូចអូសមឹក | 32.2 | 3 | 11.1 | 19.9% |
| | | លបក្តាម | 30.5 | 9 | 20.3 | 22.2% |
| | | សន្ទូចរនងចាប់មឹក | 26.9 | 2 | 23.9 | **62.8%** |
| | | លបត្រីម្រើមព្រះ | 23.0 | 9 | 12.8 | 18.6% |
| | | ឈិបយន្ត | 20.9 | 4 | 3.8 | 9.0% |
| | | លបមឹក | 14.8 | 5 | 1.7 | 5.2% |
| | | មងក្តាម | 12.9 | 40 | 17.7 | 21.7% |
| | | ឈ្នាងអូសគ្រែងឈាម | 7.7 | 10 | 4.8 | 19.9% |

| | | | | | | |
|---|---|---|---|---|---|---|
| | ខ្នាតតូច | សន្ទូចអូសមឹក | 84.4 | 6 | 105.8 | **51.1%** |
| | | មងត្រីកាម៉ុង | 56.9 | 8 | 37.5 | 23.3% |
| | | ឈិបយន្ត | 21.7 | 10 | 6.8 | 9.9% |
| | | លបត្រីម្រីមព្រះ | 21.3 | 12 | 8.6 | 11.7% |
| | | សន្ទូចរនងចាប់មឹក | 15.5 | 11 | 21.6 | **42.1%** |
| | | មងបង្គា | 11.7 | 3 | 7.6 | **37.8%** |
| | | សន្ទូចត្រី | 11.0 | 2 | 4.2 | **27.3%** |
| | | លបមឹក | 10.7 | 2 | 1.0 | 6.7% |
| | | មងត្រី | 6.4 | 5 | 2.2 | 15.3% |
| | | មងក្តាម | 5.8 | 44 | 6.0 | 15.7% |
| | | លបក្តាម | 2.8 | 3 | 2.0 | **41.2%** |
| | | | | | | |
| **ព្រះសីហនុ** | **ខ្នាតមធ្យម** | ទូកអួនអូស | 371.4 | 292 | 351.0 | 5.5% |
| | | មងត្រីកាម៉ុង | 191.3 | 15 | 80.8 | 10.9% |
| | | រនងខ្យងចាប់មឹកពីងពាង | 46.4 | 4 | 8.8 | 9.5% |
| | | មងបង្គា | 43.7 | 53 | 11.2 | 3.5% |
| | | មងត្រីផ្ទោង | 37.5 | 3 | 2.5 | 3.8% |
| | | មងក្តាម | 23.5 | 14 | 11.9 | 13.5% |
| | **ខ្នាតតូច** | មងក្តាម | 21.0 | 6 | 4.0 | 7.9% |

ឧបសម្ព័ន្ធទី៤. ផលនេសាទតាមប្រភេទ តាមខេត្ត

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| *Encrasicholina heteroloba* | Shorthead anchovy | កាកឹម | 5.8% | 94.2% | 0.0% | 0.0% | 286,375.0 | 42.4% |
| | Other fish nei | ប្រភេទត្រីចំរុះ | 68.6% | 28.4% | 2.0% | 1.0% | 78,184.5 | 11.6% |
| | Shellfish nei | ងាវចំរុះ | 100.0% | 0.0% | 0.0% | 0.0% | 58,131.0 | 8.6% |
| | trash fish | ត្រីជី | 26.9% | 70.5% | 0.1% | 2.5% | 38,840.0 | 5.8% |
| | Octopus nei | មឹកពីងពាង | 56.4% | 30.8% | 3.9% | 8.9% | 24,349.3 | 3.6% |
| *Decapterus macrosoma* | Shortfin scad | ត្រីកាម៉ុងឬត្រីប្លាធូ | 0.0% | 81.1% | 18.9% | 0.0% | 22,740.5 | 3.4% |
| | Squids nei | មឹក | 73.6% | 25.6% | 0.6% | 0.3% | 19,713.0 | 2.9% |
| *Rastrelliger brachysoma* | Short mackerel | ត្រីផ្លាធូ ឬត្រីកាម៉ុងខ្លួនខ្លី | 50.4% | 33.0% | 16.5% | 0.1% | 19,117.5 | 2.8% |
| *Portunus pelagicus* | Swimming crab | ក្ដាមសេះ | 32.0% | 28.1% | 14.1% | 25.8% | 13,970.6 | 2.1% |
| | Cephalopods (squids/cuttlefish) | ពពួកមឹកស្នូកនិងមឹកបំពង់ | 67.2% | 32.3% | 0.3% | 0.3% | 11,479.2 | 1.7% |
| | Needlefish nei | ត្រីផ្ទោង | 0.0% | 4.7% | 94.3% | 1.0% | 11,203.0 | 1.7% |
| *Penaeus sp.* | Prawns nei | បង្គា | 34.4% | 51.2% | 0.8% | 13.6% | 10,893.5 | 1.6% |
| | Other catch nei | ផ្សេងៗ | 0.0% | 0.0% | 99.5% | 0.5% | 10,596.6 | 1.6% |
| | Shrimps (unsorted) | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | 48.0% | 52.0% | 0.0% | 0.1% | 6,959.0 | 1.0% |
| | Tuna | ត្រីឈាម | 100.0% | 0.0% | 0.0% | 0.0% | 5,800.0 | 0.9% |
| *Rastrelliger faughni* | Island mackerel | ត្រីប៉ាឡាំង | 0.8% | 0.0% | 99.2% | 0.0% | 5,775.0 | 0.9% |
| *Anodontostoma chacunda* | Chacunda gizzard shad | ត្រីកាម៉យ | 0.0% | 6.5% | 93.2% | 0.3% | 5,612.0 | 0.8% |
| *Metapenaeus spp.* | | បង្គាឪខាក់ | 22.8% | 76.9% | 0.3% | 0.0% | 5,457.2 | 0.8% |
| | Small mixed shrimp nei | គី | 0.0% | 100.0% | 0.0% | 0.0% | 4,334.0 | 0.6% |
| *Rastrelliger kanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង | 1.6% | 0.0% | 98.4% | 0.0% | 4,020.0 | 0.6% |

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| *Suborder Sepiina* | Cuttlefish | មឹកស្នូក | 36.0% | 52.9% | 5.3% | 5.8% | 3,606.8 | 0.5% |
| *scomberoides tala* | Barred queenfish | ត្រីកាឡាំង | 44.4% | 0.0% | 55.6% | 0.0% | 2,700.0 | 0.4% |
| | Mollusks nei | សប្បុរសត្វ ពពួកខ្យង គ្រំ ងាវ | 76.5% | 10.1% | 0.0% | 13.4% | 2,280.7 | 0.3% |
| *Lutjanus bohar* | two-spot red snapper | ត្រីអាំងកឺយអុចពីរ | 99.6% | 0.0% | 0.4% | 0.0% | 2,256.0 | 0.3% |
| *Siganus canaliculatus* | Whitespotted Spinefoot | ត្រីកន្ទាំងក្រអូម | 50.2% | 0.0% | 49.8% | 0.0% | 2,073.0 | 0.3% |
| *Scomberoides commersonianus* | Talang queenfish | ត្រីកាឡាំង | 85.9% | 0.0% | 13.4% | 0.6% | 1,862.0 | 0.3% |
| *Hemiramphus far* | Blackbarred halfbeak | ត្រីផ្ទោងផ្កា | 0.0% | 0.0% | 99.9% | 0.1% | 1,501.0 | 0.2% |
| *Portunus spp.* | Swimming crabs | ក្ដាមសេះ | 97.2% | 2.2% | 0.2% | 0.4% | 1,440.0 | 0.2% |
| *Penaeus merguiensis* | Banana shrimp | បង្គាប៉ាវ៉ា | 99.9% | 0.0% | 0.0% | 0.1% | 1,121.0 | 0.2% |
| *Lutjanus argentimaculatus* | Mangrove red snapper | ត្រីអាំងកឺយក្រហម | 100.0% | 0.0% | 0.0% | 0.0% | 1,015.0 | 0.2% |
| *Tylosurus acus melanotus* | Aguion needlefish | ត្រីផ្ទោងព្រៃត្រ | 0.0% | 0.0% | 99.9% | 0.1% | 1,000.7 | 0.15% |
| *Epinephelus coioides* | Orange-spotted grouper | ត្រីតុកកែកៅ | 98.5% | 1.5% | 0.0% | 0.0% | 888.0 | 0.13% |
| | squirrelfish | ត្រីក្រហម | 0.0% | 0.0% | 100.0% | 0.0% | 690.0 | 0.10% |
| | Parrot fish | ត្រីសេក | 14.7% | 35.2% | 33.9% | 16.3% | 682.0 | 0.10% |
| | Mantis shrimp | បង្កងកណ្ដូប | 14.6% | 4.8% | 80.3% | 0.3% | 638.3 | 0.09% |
| | Crabs nei | ក្ដាមផ្សេងៗ | 22.1% | 0.0% | 0.0% | 77.9% | 632.5 | 0.09% |
| *Sardinella gibbosa* | goldstripe sardine | ត្រីគូន | 99.1% | 0.0% | 0.0% | 0.9% | 535.0 | 0.08% |
| | Swimming and mud crabs | ពពួកក្ដាម (រួមទាំងក្ដាមសេះ ក្ដាមថ្ម ក្ដាមជ័រ ជាដើម) | 74.9% | 6.2% | 0.0% | 18.9% | 530.0 | 0.08% |
| | Rabbitfish | ត្រីកន្ទាំង | 84.5% | 1.7% | 13.9% | 0.0% | 361.0 | 0.05% |
| *Carangoides bajad* | Orangespotted trevally | ត្រីផែកាម | 100.0% | 0.0% | 0.0% | 0.0% | 360.0 | 0.05% |

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| *Nemipterus furcosus* | Forktailed Threadfin Bream | ត្រីក្រហមស្រកាទន់ | 98.7% | 0.0% | 0.0% | 1.3% | 304.0 | 0.05% |
| *Decapterus maruadsi* | Round scad | ត្រីកូនគុំ | 100.0% | 0.0% | 0.0% | 0.0% | 300.0 | 0.04% |
| | Rays nei | បបែល | 0.0% | 19.8% | 80.2% | 0.0% | 299.8 | 0.04% |
| | Lizardfish | ត្រីក្តចិន | 37.7% | 6.8% | 55.5% | 0.0% | 292.0 | 0.04% |
| | Barracuda | ត្រីអង្រែ | 100.0% | 0.0% | 0.0% | 0.0% | 290.0 | 0.04% |
| | Shrimps nei | បង្កងប៉ាក | 27.5% | 67.1% | 0.0% | 5.3% | 261.7 | 0.04% |
| *Rachycentron canadum* | Cobia | ត្រីផ្ទក់សមុទ្រ | 98.8% | 0.0% | 0.0% | 1.2% | 253.0 | 0.04% |
| | Octopus | មឹកពីងពាង | 100.0% | 0.0% | 0.0% | 0.0% | 250.0 | 0.04% |
| | Pony fishes | ត្រីកិ | 0.0% | 72.4% | 23.3% | 4.3% | 232.0 | 0.03% |
| *Episesarma versicolor* | Violet vinegar crab | ក្តាមជ័រ | 90.5% | 0.0% | 0.0% | 9.5% | 188.5 | 0.03% |
| *Crenimugil seheli* | Bluespot mullet | ត្រីក្បក | 3.2% | 0.0% | 96.8% | 0.0% | 154.0 | 0.02% |
| *Sillago sihama* | Silver sillago | ត្រីព្រលួស | 2.0% | 0.0% | 17.5% | 80.5% | 151.0 | 0.02% |
| *Lutjanus gibbus* | humpback red snapper | ត្រីឆ្កុងក្រហម | 100.0% | 0.0% | 0.0% | 0.0% | 150.0 | 0.02% |
| | Snappers, jobfishes | ត្រីអាំងកឹយ | 100.0% | 0.0% | 0.0% | 0.0% | 150.0 | 0.02% |
| *Sargocentron rubrum* | Redcoat | ត្រីកាជី | 100.0% | 0.0% | 0.0% | 0.0% | 120.0 | 0.02% |
| | Cephalopods (squids/cuttlefish) | មឹកហួយសាយ | 100.0% | 0.0% | 0.0% | 0.0% | 120.0 | 0.02% |
| *Pseudorhombus arsius* | Largetooth flounder | ត្រីអណ្តាតឆ្កែ | 20.3% | 68.9% | 0.0% | 10.8% | 111.0 | 0.02% |
| *Eleutheronema tetradactylum* | Fourfinger threadfin | ត្រីកា៉រាវ | 24.0% | 0.0% | 67.8% | 8.2% | 97.4 | 0.01% |
| *Brevitrygon imbricata* | Scaly whipray | បបែលមាន់ | 0.0% | 0.5% | 0.0% | 99.5% | 92.5 | 0.01% |
| *Penaeus monodon* | Giant tiger prawn | បង្គាខ្លឹង | 0.0% | 33.3% | 0.0% | 66.7% | 91.5 | 0.01% |
| *Anadara granosa* | Blood cockle | គ្រែងឈាម | 93.0% | 0.0% | 0.0% | 7.0% | 86.0 | 0.01% |

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| *Alepes vari* | Herring scad | ត្រីកាហាវ | 0.0% | 0.0% | 0.0% | 100.0% | 85.0 | 0.01% |
| *Scylla serrata* | Mud crab | ក្តាមថ្ម | 52.4% | 0.0% | 0.0% | 47.6% | 84.1 | 0.01% |
| *Nemipterus hexodon* | Ornate treadfin bream | ត្រីអាងគីមលី | 100.0% | 0.0% | 0.0% | 0.0% | 80.0 | 0.01% |
| | Congers nei | អន្ទង់សមុទ្រ | 0.0% | 0.0% | 0.0% | 100.0% | 65.0 | 0.01% |
| *Megalaspis cordyla* | Torpedo scad | ត្រីកន្ទុយរឹង | 0.0% | 0.0% | 96.8% | 3.2% | 63.0 | 0.01% |
| *Chiloscyllium griseum* | Grey bambooshark | ឆ្លាមគីង្គក់ឬឆ្លាមឆ្កួត | 0.0% | 0.0% | 0.0% | 100.0% | 62.0 | 0.01% |
| *Lutjanus malabaricus* | Malabar blood snapper | ត្រីក្រហម | 0.0% | 0.0% | 100.0% | 0.0% | 50.0 | 0.01% |
| *Scomberomorus commerson* | Narrowbarred Spanish mackerel | ត្រីបេកាខ្មៅ ឫត្រីបេកាឆ្នូត | 78.3% | 0.0% | 21.7% | 0.0% | 46.0 | 0.01% |
| | Emperors, scavengers nei | ត្រីគ្រាប់ខ្នុរ | 0.0% | 0.0% | 100.0% | 0.0% | 42.0 | 0.01% |
| *Scomberomorus sp.* | Spanish mackerel species nei | ត្រីបេកា | 23.1% | 41.0% | 30.8% | 5.1% | 39.0 | 0.01% |
| *Myrophis microchir* | Ordinary Snake eel | អន្ទង់សមុទ្រ | 0.0% | 0.0% | 0.0% | 100.0% | 37.0 | 0.01% |
| *Arius maculatus* | Spotted catfish | ត្រីក្អុក | 94.4% | 0.0% | 5.6% | 0.0% | 36.0 | 0.01% |
| *Leiognathus smithhursti* | Smithhurst's ponyfish | ត្រីកិខ្លួនខ្លី | 0.0% | 0.0% | 0.0% | 100.0% | 30.0 | 0.004% |
| *Pampus argenteus* | Silver pomfret | ត្រីចាបស | 0.0% | 0.0% | 0.0% | 100.0% | 29.0 | 0.004% |
| *Sillago aeolus* | Oriental sillago | ត្រីព្រលួសផ្កា | 0.0% | 0.0% | 0.0% | 100.0% | 25.0 | 0.004% |
| *Maculabatis gerrardi* | Whitespottted whipray | បបែលអុជ | 0.0% | 0.0% | 22.7% | 77.3% | 22.0 | 0.003% |
| *Lactarius lactarius* | False trevally | ត្រីស្លឹកខ្នុរ | 0.0% | 0.0% | 100.0% | 0.0% | 20.0 | 0.003% |
| *Gazza minuta* | Toothpony | ត្រីសំបោរហៀរ "គ្មានរំអិល" | 100.0% | 0.0% | 0.0% | 0.0% | 20.0 | 0.003% |
| *Albula neoguinaica* | Sharpjaw bonefish | ត្រីបេកា | 0.0% | 0.0% | 100.0% | 0.0% | 20.0 | 0.003% |
| | Flounders and soles nei | ត្រីអណ្តាតឆ្កែ | 16.2% | 0.0% | 83.8% | 0.0% | 18.5 | 0.003% |
| *Diagramma pictum* | Painted sweetlips | ត្រីកាជី | 0.0% | 0.0% | 41.2% | 58.8% | 17.0 | 0.003% |

| ឈ្មោះវិទ្យាសាស្រ្ត | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| | Pomfrets | ត្រីចាប | 100.0% | 0.0% | 0.0% | 0.0% | 15.0 | 0.002% |
| | Mullets | ត្រីក្បក | 0.0% | 0.0% | 100.0% | 0.0% | 14.0 | 0.002% |
| | Sharks | ឆ្លាម | 0.0% | 100.0% | 0.0% | 0.0% | 12.5 | 0.002% |
| *Sillago ingenuua* | Bay sillago | ត្រីព្រលួសធម្មតា | 0.0% | 0.0% | 0.0% | 100.0% | 10.0 | 0.001% |
| *Scarus ghobban* | Blue-barred parrotfish | ត្រីសេកស្រកាលឿង | 0.0% | 0.0% | 0.0% | 100.0% | 10.0 | 0.001% |
| *Karalla daura* | Goldstripe ponyfish | ត្រីសំបោរហៀររំអិល | 100.0% | 0.0% | 0.0% | 0.0% | 10.0 | 0.001% |
| | Drums and croakers nei | ត្រីចង្ហួមបី | 0.0% | 0.0% | 100.0% | 0.0% | 10.0 | 0.001% |
| *Cheilinus diagrammus* | Cheeklinedmaori wrasse | ត្រីសេកថ្ពាល់ឆ្នូត | 0.0% | 0.0% | 0.0% | 100.0% | 9.5 | 0.001% |
| *Acanthurus sp.* | Surgeonfish | ត្រីកាតាំង | 37.5% | 0.0% | 62.5% | 0.0% | 8.0 | 0.001% |
| | Threadfins nei | ត្រីកាវ៉ាវ | 0.0% | 0.0% | 100.0% | 0.0% | 7.0 | 0.001% |
| *Terapon jarbua* | Jarbua terapon | ត្រីត្រសក់កន្ទុយឆែក | 0.0% | 0.0% | 50.0% | 50.0% | 6.0 | 0.001% |
| *Epinephelus amblycephalus* | Banded grouper | ត្រីតុកកែខ្លា | 0.0% | 0.0% | 0.0% | 100.0% | 5.5 | 0.001% |
| *Sphyraena obtusata* | Obtuse barracuda | ត្រីអង្រែ | 0.0% | 0.0% | 80.0% | 20.0% | 5.0 | 0.001% |
| *Saurida undosquamis* | Bushtooth lizarfish | ត្រីក្តចិនអុជខ្មៅ | 0.0% | 100.0% | 0.0% | 0.0% | 5.0 | 0.001% |
| *Otolithes ruber* | Tigertooth Croaker | ត្រីចង្ហួមបី | 0.0% | 0.0% | 100.0% | 0.0% | 4.0 | 0.001% |
| *Anampses geographicus* | Geographic wrasse | ត្រីកសេក | 0.0% | 0.0% | 100.0% | 0.0% | 4.0 | 0.001% |
| *Leiognathus leuciscus* | Whipfin ponyfish | ត្រីកិ | 0.0% | 100.0% | 0.0% | 0.0% | 3.0 | 0.0004% |
| *Thryssa hamiltonii* | Hamilton's thryssa | ត្រីស្លឹកឬស្សី | 0.0% | 100.0% | 0.0% | 0.0% | 2.0 | 0.0003% |
| *Thalamita crenata* | Crenate swimming crab | ក្តាមថ្មខៀវ | 0.0% | 0.0% | 0.0% | 100.0% | 2.0 | 0.0003% |
| *Saurenchelys cancrivora* | Slender Sorcerer | ត្រីខ្ទីងសមុទ្រ | 0.0% | 0.0% | 0.0% | 100.0% | 2.0 | 0.0003% |
| *Chiloscyllium punctatum* | Brownbanded bambooshark | ឆ្លាមឆ្នូត | 0.0% | 0.0% | 100.0% | 0.0% | 2.0 | 0.0003% |

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កោះកុង | ព្រះសីហនុ | កំពត | កែប | ផលចាប់ (គ.ក្រ) | ផលចាប់ (%) |
|---|---|---|---|---|---|---|---|---|
| | Bivalves nei | ឆ្លាម បំបែល | 0.0% | 0.0% | 100.0% | 0.0% | 2.0 | 0.0003% |
| | Morray eels nei | អន្ទង់សមុទ្រ | 0.0% | 0.0% | 0.0% | 100.0% | 2.0 | 0.0003% |
| | Terapons | ត្រីត្រសក់ | 0.0% | 0.0% | 100.0% | 0.0% | 1.0 | 0.0001% |
| *Stolephorus indicus* | Indian anchovy | ត្រីក្រចកក្របី | 0.0% | 100.0% | 0.0% | 0.0% | 0.3 | 0.00004% |
| **សរុបរួម** | | | **32.8%** | **57.2%** | **8.3%** | **1.7%** | **674,760.7** | |

ឧបសម្ព័ន្ធទី៥. សមាសភាគរាយការណ៍ប្រចាំខែទៅនឹងផលនេសាទតាមប្រភេទប្រចាំឆ្នាំ សម្រាប់ប្រភេទកំពូលគេទាំង២០

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | Jun | Jul | Aug | Sep | Oct | Nov | Dec | Total (kg) | Total (%) |
|---|---|---|---|---|---|---|---|---|---|---|---|
| *Encrasicholina heteroloba* | កាកឹម | Shorthead anchovy | 25.9% | 35.5% | 7.7% | 11.9% | 12.4% | 3.7% | 2.9% | 286,375.0 | 42.4% |
| | ប្រភេទត្រីចំរុះ | Other fish nei | 6.3% | 14.0% | 12.8% | 14.6% | 21.8% | 13.6% | 16.9% | 78,184.5 | 11.6% |
| | ខ្យង មឹក ក្តាមផ្សេងៗ | Shellfish nei | 0.5% | 23.1% | 1.0% | 0.0% | 59.0% | 1.4% | 14.9% | 57,328.0 | 8.5% |
| | ត្រីជី | Trash fish | 6.1% | 5.9% | 9.7% | 43.7% | 9.1% | 19.1% | 6.3% | 38,840.0 | 5.8% |
| | មឹកពីងពាង | Octopus nei | 11.6% | 11.4% | 11.4% | 23.5% | 11.9% | 18.4% | 12.0% | 24,599.3 | 3.6% |
| *Decapterus macrosoma* | ត្រីកាម៉ុងឬត្រីប្លាធូ | Shortfin scad | 0.0% | 4.4% | 2.2% | 20.9% | 32.6% | 30.8% | 9.0% | 22,740.5 | 3.4% |
| | មឹក | Squids nei | 29.9% | 12.2% | 8.7% | 12.0% | 10.9% | 10.2% | 16.0% | 19,713.0 | 2.9% |
| *Rastrelliger brachysoma* | ត្រីផ្លាធូ ឬត្រីកាម៉ុងខ្លួនខ្លី | Short mackerel | 2.4% | 0.0% | 12.4% | 43.1% | 0.7% | 22.1% | 19.4% | 19,117.5 | 2.8% |
| *Portunus pelagicus* | ក្តាមសេះ | Swimming crab | 9.6% | 11.1% | 24.9% | 9.0% | 23.6% | 10.8% | 11.0% | 13,970.6 | 2.1% |
| | ពពួកមឹកស្នូកនិងមឹកបំពង់ | Squids & cuttlefish nei | 9.6% | 28.0% | 3.6% | 4.4% | 25.2% | 7.3% | 21.8% | 11,479.2 | 1.7% |
| | ត្រីផ្ទោង | Needlefish nei | 8.3% | 18.0% | 10.9% | 14.9% | 10.7% | 13.1% | 24.1% | 11,203.0 | 1.7% |
| *Penaeus sp.* | បង្គា | Prawns nei | 10.0% | 3.6% | 43.5% | 18.2% | 12.0% | 8.0% | 4.8% | 10,893.5 | 1.6% |
| | ប្រភេទត្រីចំរុះ | Other fish nei | 11.5% | 8.4% | 17.2% | 15.6% | 18.4% | 17.7% | 11.2% | 10,596.6 | 1.6% |
| | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | Shrimps nei | 3.4% | 36.6% | 5.3% | 11.6% | 23.3% | 11.8% | 7.9% | 6,959.0 | 1.0% |
| | ត្រីឈាម | Tuna | 0.0% | 0.0% | 13.8% | 0.0% | 86.2% | 0.0% | 0.0% | 5,800.0 | 0.9% |
| *Rastrelliger faughni* | ត្រីប៉ាឡាំង | Island mackerel | 2.3% | 0.0% | 31.9% | 0.0% | 36.4% | 29.4% | 0.0% | 5,775.0 | 0.9% |
| *Metapenaeus spp.* | បង្គាឪខាក់ | | 9.8% | 19.8% | 17.5% | 21.4% | 7.0% | 8.2% | 16.4% | 5,457.2 | 0.8% |
| *Anodontostoma chacunda* | ត្រីកាម៉យ | Chacunda gizzard shad | 20.7% | 18.0% | 16.3% | 10.5% | 20.0% | 10.0% | 4.5% | 5,279.0 | 0.8% |
| | គី | Small mixed shrimp nei | 7.2% | 22.3% | 18.1% | 28.2% | 10.4% | 6.6% | 7.2% | 4,334.0 | 0.6% |
| *Rastrelliger kanagurta* | ត្រីកាម៉ុងខ្លួនវែង | Indian mackerel | 14.9% | 47.4% | 8.7% | 21.3% | 7.5% | 0.2% | 0.0% | 4,020.0 | 0.6% |

ឧបសម្ព័ន្ធទី៦. ផលនេសាទរាយការណ៍តាមទីតាំងនេសាទនិងតាមខេត្តសំខាន់ៗ

| ឧបករណ៍នេសាទខ្នាតតូច | សមុទ្រក្នុង | សមុទ្រក្រៅ | ទាំងពីរទីតាំង | ផលនេសាទសរុប (គ.ក្រ) |
|---|---|---|---|---|
| កំពត | 82.6% | 17.4% | 0.0% | 6,891.8 |
| កែប | 100.0% | 0.0% | 0.0% | 1,524.0 |
| កោះកុង | 36.8% | 0.0% | 63.2% | 5,775.0 |
| ព្រះសីហនុ | 26.0% | 28.7% | 45.2% | 1,044.5 |
| **សរុបរួម** | **63.1%** | **9.8%** | **27.1%** | **15,235.3** |
| | | | | |
| ទូកអួនអូស | **សមុទ្រក្នុង** | **សមុទ្រក្រៅ** | **ទាំងពីរទីតាំង** | **ផលនេសាទសរុប (គ.ក្រ)** |
| កំពត | 99.1% | 0.0% | 0.9% | 6,892.0 |
| កែប | 100.0% | 0.0% | 0.0% | 3,938.0 |
| កោះកុង | 2.5% | 57.8% | 39.7% | 167,268.7 |
| ព្រះសីហនុ | 35.5% | 56.1% | 8.4% | 351,889.7 |
| **សរុបរួម** | **26.4%** | **55.5%** | **18.1%** | **529,988.4** |
| | | | | |
| ឧបករណ៍ខ្នាតមធ្យមផ្សេងទៀត | **សមុទ្រក្នុង** | **សមុទ្រក្រៅ** | **ទាំងពីរទីតាំង** | **ផលនេសាទសរុប (គ.ក្រ)** |
| កំពត | 11.8% | 88.2% | 0.0% | 42,355.4 |
| កែប | 91.5% | 8.5% | 0.0% | 5,888.9 |
| កោះកុង | 18.9% | 6.0% | 75.1% | 48,069.5 |
| ព្រះសីហនុ | 21.6% | 51.5% | 26.9% | 33,151.2 |
| **សរុបរួម** | **20.6%** | **44.7%** | **34.8%** | **129,465.0** |

ឧបសម្ព័ន្ធទី៧. សមាសភាគផលនេសាទតាមប្រភេទដោយទូកអួនអូស រួមចំណែកយ៉ាងតិច ៧០% នៃផលនេសាទ

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | សរុប | អួនអូស% |
|---|---|---|---|---|
| *Encrasicholina heteroloba* | កាកឹម | Shorthead anchovy | 286,375.0 | 100.0% |
| | ប្រភេទត្រីចំរុះ | Other fish nei | 78,182.5 | 91.6% |
| | ខ្យង ម៉ឹក ក្តាមផ្សេងៗ | Shellfish nei | 57,328.0 | 99.9% |
| | ត្រីជី | trash fish | 38,840.0 | 97.8% |
| | ពពួកមឹកស្នូកនិងមឹកបំពង់ | Cephalopods (squids/cuttlefish) | 11,479.2 | 91.2% |
| *Penaeus sp.* | បង្គា | Prawns nei | 10,893.5 | 72.7% |
| | ពពួកបង្គាគ្រប់ប្រភេទទាំងអស់ | Shrimps (all kinds of shrimps) | 6,959.0 | 99.7% |
| | ត្រីឈាម | Tuna | 5,800.0 | 100.0% |
| *Metapenaeus spp.* | បង្គាឪខាក់ | | 5,457.2 | 77.8% |
| | គី | Small mixed shrimp nei | 4,334.0 | 100.0% |
| *Suborder Sepiina* | មឹកស្នូក | Cuttlefish | 3,606.8 | 76.8% |
| *Penaeus merguiensis* | បង្គាប៉ាវ៉ា | Banana shrimp | 1,121.0 | 99.9% |
| | ងាវចំរុះ | Shellfish nei | 803.0 | 100.0% |
| | ត្រីសេក | Parrot fish | 682.0 | 90.9% |
| | ក្តាមផ្សេងៗ | Crabs nei | 632.5 | 75.3% |
| *Sardinella gibbosa* | ត្រីគូន | goldstripe sardine | 535.0 | 99.1% |
| *Carangoides bajad* | ត្រីផៃកាម | Orangespotted trevally | 360.0 | 83.3% |
| *Decapterus maruadsi* | ត្រីកូនគុំ | Round scad | 300.0 | 100.0% |
| | ត្រីអង្រែ | Barracuda | 290.0 | 100.0% |
| | ត្រីកិ | Pony fishes | 232.0 | 73.3% |
| *Sargocentron rubrum* | ត្រីកាជី | Redcoat | 120.0 | 100.0% |
| *Penaeus monodon* | បង្គាខ្លឹង | Giant tiger prawn | 91.5 | 86.9% |
| | អន្ទង់សមុទ្រ | Congers nei | 65.0 | 81.5% |
| *Chiloscyllium griseum* | ឆ្លាមគីង្គក់ឬឆ្លាមឆ្កួត | Grey bambooshark | 62.0 | 87.1% |
| *Pampus argenteus* | ត្រីចាបស | Silver pomfret | 29.0 | 75.9% |
| *Episesarma sp.* | ក្តាមជ័រ | Vinegar crab | 22.0 | 72.7% |
| | ត្រីចាប | Pomfrets | 15.0 | 100.0% |
| *Karalla daura* | ត្រីសំបោរហៀររំអិល | Goldstripe ponyfish | 10.0 | 100.0% |
| *Sphyraena obtusata* | ត្រីអង្រែ | Obtuse barracuda | 5.0 | 100.0% |
| *Saurida undosquamis* | ត្រីក្តចិនអុជខ្មៅ | Bushtooth lizarfish | 5.0 | 100.0% |
| *Anampses geographicus* | ត្រីកសេក | Geographic wrasse | 4.0 | 100.0% |
| *Saurenchelys cancrivora* | ត្រីខ្លឹងសមុទ្រ | Slender Sorcerer | 2.0 | 100.0% |
| | ឆ្លាម បំបែល | Shellfish (bivalves nei) | 2.0 | 100.0% |
| | ត្រីត្រសក់ | Terapons | 1.0 | 100.0% |